ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខ.១១៦/........២០២១

# របាយការណ៍ខែមិថុនា
# ស្តីពី
# ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ
# និងទិសដៅខែកក្កដា ឆ្នាំ២០២១

## I. ស្ថានភាពទូទៅ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស របស់ក្រសួង ស្ថាប័ន រាជធានី ខេត្ត បានបន្តសកម្មភាព របស់ខ្លួនទៅតាមទិសដៅគ្រោងទុក បើទោះបីជាបាននិងកំពុងតែប្រឈមនឹងសភាពការណ៍វិវត្តថ្មី ដែលមិនអាចប៉ាន់ស្មានបាន ពាក់ព័ន្ធនឹងស្ថានភាពប្រែប្រួលនៃសេដ្ឋកិច្ចពិភពលោក និងបន្ថែមដោយវិបត្តិនៃការរាតត្បាតដោយជំងឺកូវីដ១៩។

ក្រសួង ស្ថាប័ន និងរាជធានី ខេត្ត បានបន្តទិសដៅការងារ ផ្តោតការយកចិត្តទុកដាក់បន្ថែម ទៅលើបញ្ហាវិបត្តិកូវីដ១៩ ដែលជាភាពប្រឈមថ្មី និងដែលជះឥទ្ធិពលដល់ការអនុវត្តសកម្មភាពគ្រប់វិស័យ ធ្វើឱ្យរាំងស្ទះដោយអន្លើ និងត្រូវបន្ថែមភារកិច្ច ក្នុងការដោះស្រាយទប់ស្កាត់ផលប៉ះពាល់ លើជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ជាពិសេសអ្នកដែលវិលត្រឡប់ពីប្រទេសក្រៅ ដែលមានចំនួនច្រើនលើសលប់ និងភាគច្រើន ជាអ្នកដែលខ្វះលទ្ធភាព ក្នុងការទ្រទ្រង់ជីវភាព ហើយងាយរងគ្រោះ។ ការជួយសង្គ្រោះពលករដែលវិលត្រឡប់មកពីក្រៅប្រទេស គឺជាកិច្ចការចាំបាច់ ដើម្បីបង្ការទប់ស្កាត់ ការនាំចូលជំងឺកូវីដ១៩ ទៅក្នុងសហគមន៍ និងការដោះស្រាយភាពប្រឈមក្នុងពេលធ្វើសមាហរណកម្មទៅក្នុងសហគមន៍ ព្រមទាំងទប់ស្កាត់ការបាញ់បោកមេខ្យល់ ក្នុងការនាំពលករត្រឡប់ទៅប្រទេសគោលដៅវិញ ក្នុងស្ថានភាពដែលមានការរឹតបន្តឹងពីប្រទេសគោលដៅ ដើម្បីការពារជំងឺរាតត្បាត និងវិបត្តិសេដ្ឋកិច្ចដែលកើតមានទូទាំងពិភពលោក ដែលធ្វើឱ្យពលករខាតបង់រឹតតែធ្ងន់ធ្ងរ និងធ្លាក់ទៅក្នុងរលកថ្មីនៃអំពើជួញដូរមនុស្ស។

អាជ្ញាធរ សមត្ថកិច្ច និងលេខាធិការដ្ឋាន នៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ និងអង្គការដៃគូ បានធ្វើសកម្មភាពយ៉ាងមមាញឹក ប្រចាំការនៅតាមព្រំដែនទទួលសង្គ្រោះពលករ ដែលវិលត្រឡប់តាមច្រកមិនផ្លូវការ ទាំងយប់ទាំងថ្ងៃ ពិនិត្យកម្តៅ និងផ្តល់សេវាសុខភាព អនុវត្តគោលការណ៍ចត្តាឡីស័កតាមវិធានសុខាភិបាល ផ្តល់អាហារ ត្រៀមមធ្យោបាយដឹកជញ្ជូន ឱ្យបានដល់លំនៅដ្ឋាន និងបន្តតាមដានស្ថានភាពសុខភាពជីវភាព និងផ្តល់សេវាតាមតម្រូវការផ្សេងៗ និងបន្តតាមដានស្ថានភាព នៅពេលធ្វើសមាហរណកម្មទៅក្នុងសហគមន៍ដែលពួកគាត់រស់នៅ។ លើសពីនេះទៅទៀត វិធានការអប់រំ បង្ការទប់ស្កាត់សកម្មភាពវិលត្រឡប់ទៅប្រទេសថៃវិញ ក្នុងអំឡុងពេលដែលមានការរឹតបន្តឹង ពីប្រទេសគោលដៅក្នុងវិធានការទប់ស្កាត់វិបត្តិកូវីដ១៩ និងដោះស្រាយវិបត្តិសេដ្ឋកិច្ច ការបង្កើនការស៊ើបអង្កេតរកមេខ្យល់ជួញដូរមនុស្ស ក្នុងដំណាក់កាលនេះ ការផ្តល់សេវាជួយជនរងគ្រោះ និងជនងាយរងគ្រោះ ត្រូវបានធ្វើឡើងកាន់តែសកម្ម។

ដើម្បីឆ្លើយតបទៅនឹងបញ្ហាដែលកើតមានខាងលើនេះ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមានអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ជាសេនាធិការ បានបង្កើនការយកចិត្តទុកដាក់ សម្របសម្រួល ពង្រឹងកិច្ចសហការជាមួយក្រសួង ស្ថាប័ន ជាសមាជិក និងជំរុញសកម្មភាពគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរាជធានី-ខេត្ត មន្ទីរ អង្គភាព និងដៃគូជាតិ អន្តរជាតិ ក៏ដូចជាសមត្ថកិច្ចនៃប្រទេសពាក់ព័ន្ធ ដើម្បីធ្វើសកម្មភាព និងកិច្ចប្រតិបត្តិការដើម្បីដោះស្រាយបញ្ហារួមគ្នា ដោយទទួលបានលទ្ធផល ដូចខាងក្រោម៖

## II. លទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

### ក. ការងារ ច្បាប់ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ការអនុវត្តច្បាប់ និងការលើកកម្ពស់កិច្ចសហប្រតិបត្តិការ

#### ក.១. ការកសាងច្បាប់

- ក្រសួងយុត្តិធម៌ និងក្រសួងកិច្ចការនារី បានដឹកនាំធ្វើសេចក្តីព្រាងច្បាប់ ស្តីពី"**ការពពោះជំនួស**"។
- ក្រសួងយុត្តិធម៌ ៖
  - រដ្ឋសភាបានអនុម័តច្បាប់ស្តីពី"**ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ**" (MLA) (ត្រូវបានប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការណ៍ជាប្រញាប់ ដោយព្រះរាជក្រមលេខ នស/រកម ០៦២០/០២០ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២០)។
  - បានរៀបចំសេចក្តីព្រាងច្បាប់ស្តីពី "**ការប្រឆាំងអំពើរត់ពន្ធមនុស្ស**"។

#### ក.២. សន្ធិសញ្ញា

- ក្រសួងយុត្តិធម៌
  - បានកំពុងរៀបចំសេចក្តីព្រាងសន្ធិសញ្ញាទ្វេភាគី ជាមួយប្រទេសឡាវ បារាំង និងប្រទេសកូរ៉េខាងត្បូង ស្តីពី"**ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ**"
  - បានកំពុងរៀបចំសេចក្តីព្រាងសន្ធិសញ្ញាទ្វេភាគី ជាមួយប្រទេសអង់គ្លេស ប៉េរូ និងប្រទេសឡាវ ស្តីពី "**ការបញ្ជូនទណ្ឌិត**"។

#### ក.៣. គោលនយោបាយ និងអនុស្សរណៈនៃការយោគយល់គ្នា

- គណៈកម្មាធិការជាតិ គ.ជ.ប.ជ បានចុះអនុស្សរណៈយោគយល់គ្នា រវាងអង្គការវីវើលអនលូស (We World Onlus)ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២១ ដោយលោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ ជាមួយនិងប្រធានអង្គការវីវើលអនលូស នៅប្រទេសកម្ពុជា។
- ក្រសួងទេសចរណ៍ ត្រៀមចុះអនុស្សរណៈនៃការយោគយល់គ្នា ស្តីពីការអនុវត្តគម្រោងកុមារភាព ជាមួយអង្គការ Friends International។

#### ក.៤. លិខិតបទដ្ឋានគតិយុត្ត

- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា៖ ធ្វើសេចក្តីព្រាងរៀបចំអនុក្រឹត្យ ស្តីពីរបបគោលនយោបាយសម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ការរំលោភបំពានផ្លូវភេទ និងការកេងប្រវ័ញ្ចគ្រប់ទម្រង់ផ្សេងៗទៀត ដែលស្នាក់នៅមណ្ឌលសំចតរបស់រដ្ឋ និងរស់នៅតាមសហគមន៍។

#### ក.៥ ការពង្រឹងកិច្ចសហប្រតិបត្តិការ

- អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានរៀបចំ និងចូលរួមអនុវត្តគម្រោងរួមគ្នា រវាងរាជរដ្ឋាភិបាល និងអង្គការសហប្រជាជាតិ សម្រាប់ពលករវិលត្រឡប់ ក្នុងដំណាក់កាល នៃការរាតត្បាតដោយជំងឺកូវីដ១៩ នៅក្នុងខេត្ត បាត់ដំបង សៀមរាប និងបន្ទាយមានជ័យ។

### ខ. ការបង្ការ ទប់ស្កាត់

#### ខ.១. តាមរយៈការលើកកម្ពស់ការយល់ដឹង

##### ខ.១.១. ការអប់រំដោយផ្ទាល់

នៅក្នុងខែមិថុនា ឆ្នាំ២០២១នេះ ស្ថាប័នថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ អាជ្ញាធរ មន្ទីរពាក់ព័ន្ធ បានសហការជាមួយអង្គការដៃគូ ធ្វើការផ្សព្វផ្សាយ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព តាមរយៈកិច្ចប្រជុំ វេទិកាសាធារណៈ ការអនុវត្តគោលនយោបាយ "**ភូមិ-ឃុំ មានសុវត្ថិភាព**" និងកម្មវិធីផ្សេងៗ ដល់មន្ត្រីរាជការ សិស្សានុសិស្ស លោកគ្រូ-អ្នកគ្រូ សាសនិកជន និងប្រជាពលរដ្ឋ សរុបចំនួន

៨.៩១៣លើក មានអ្នកចូលរួមសរុបចំនួន ៣៥៤.០៣៦នាក់ (ធៀបនឹងខែឧសភា មានចំនួន ២៤០.៩៤០នាក់ គឺមានការកើនឡើងចំនួន ១១៣.០៩៦នាក់ ស្មើនឹង៣១,៩៤% ក្នុងនោះស្ត្រីចំនួន ១៩៧.១៧៦នាក់ ដូចមានតារាងលម្អិតខាងក្រោម៖

តារាងទិន្នន័យការអប់រំផ្សព្វផ្សាយតាមរយៈកិច្ចប្រជុំ និងវេទិកាសាធារណៈ

| ល.រ | ក្រសួង ស្ថាប័ន<br>រាជធានី-ខេត្ត | ផ្សព្វផ្សាយ | | | វេទិកាសាធារណៈ | | |
|---|---|---|---|---|---|---|---|
| | | ចំនួនដង/លើក | ចំនួនមនុស្ស | ចំនួនស្ត្រី | ចំនួនដង/លើក | ចំនួនមនុស្ស | ចំនួនស្ត្រី |
| ក្រសួង ស្ថាប័ន | | | | | | | |
| ១ | អគ្គស្នងការដ្ឋាននគរបាលជាតិ | ៣ | ៧៩ | ៤១ | ៦៥ | ១.៤៥២ | ៦៤៨ |
| សរុប ក្រសួង ស្ថាប័ន | | ៣ លើក | ៧៩ នាក់ | ៤១ នាក់ | ៦៥ លើក | ១.៤៥២ នាក់ | ៦៤៨ នាក់ |
| រាជធានី-ខេត្ត | | | | | | | |
| ១ | រាជធានីភ្នំពេញ | | | | | | |
| ២ | ខេត្តកណ្តាល | ៤៣០ | ៩.៣៦១ | ៥.១៥១ | ៦២៨ | ៣២.៣០៧ | ១៥.១៥៦ |
| ៣ | ខេត្តបាត់ដំបង | ៦៥០ | ១៧.១០៦ | ៩.១៨១ | ៤២០ | ១.០២៨ | ៥.៥៦៩ |
| ៤ | ខេត្តពោធិ៍សាត់ | ២៤៤ | ៧.៥០៥ | ៣.៧៣៥ | ៤០ | ១.៣៦៤ | ៥៩១ |
| ៥ | ខេត្តសៀមរាប | ៦៥ | ៣.៧៨៥ | ២.៣៦៧ | | | |
| ៦ | ខេត្តកំពង់ឆ្នាំង | ១.៤៦០ | ៧.៤៩៦ | ៤.៨៧៥ | ៨១២ | ១៩.៤៣២ | ១០.៦០០ |
| ៧ | ខេត្តកំពង់ចាម | ២.១៩៧ | ១៥៩.៥៤៩ | ៨៧.៦០១ | ១.៥០៥ | ៧៩.៩០៣ | ៤៣.៦៧៨ |
| ៨ | ខេត្តព្រះសីហនុ | | | | | | |
| ៩ | ខេត្តព្រះវិហារ | ១ | ៥៤ | ៣០ | | | |
| ១០ | ខេត្តស្វាយរៀង | | | | | | |
| ១១ | ខេត្តប៉ៃលិន | ៩៦ | ១.៤៤០ | ៦៧៣ | ២៤៧ | ៦.៩៤៥ | ៣.៩២១ |
| ១២ | ខេត្តកោះកុង | | | | ៣២ | ៨២៦ | ៤៥៨ |
| ១៣ | ខេត្តកំពត | ១ | ៥៥ | ១៥ | | | |
| ១៤ | ខេត្តកំពង់ធំ | | | | | | |
| ១៥ | ខេត្តតាកែវ | | | | | | |
| ១៦ | ខេត្តក្រចេះ | ៣ | ៥៧ | ៣៥ | | | |
| ១៧ | ខេត្តកែប | | | | | | |
| ១៨ | ខេត្តកំពង់ស្ពឺ | | | | | | |
| ១៩ | ខេត្តស្ទឹងត្រែង | | | | | | |
| ២០ | ខេត្តរតនគិរី | | | | | | |
| ២១ | ខេត្តព្រៃវែង | | | | | | |
| ២២ | ខេត្តត្បូងឃ្មុំ | ៤ | ៦២ | ៥៧ | | | |
| ២៣ | ខេត្តបន្ទាយមានជ័យ | | | | | | |
| ២៤ | ខេត្តឧត្តរមានជ័យ | ១០ | ៤២៣០ | ២៧៩៤ | | | |
| ២៥ | ខេត្តមណ្ឌលគិរី | | | | | | |
| សរុប រាជធានី-ខេត្ត | | ៥.១៦១លើក | ២១០.៧០០នាក់ | ១១៦.៥១៤នាក់ | ៣.៦៨៤លើក | ១៤១.៨០៥នាក់ | ៧៩.៩៧៣នាក់ |
| សរុបរួម ក្រសួង ស្ថាប័ន និងរាជធានី-ខេត្ត | | ចំនួន ៨.៩១៣ លើក | | ចំនួនមនុស្សសរុប ៣៥៤.០៣៦ នាក់ | | ចំនួនស្ត្រី ១៩៧.១៧៦ នាក់ | |

២.១.២. ការផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ និងប្រព័ន្ធអេឡិកត្រូនិក

- **ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖**
  - បានសហការជាមួយនិយ័តករទូរគមនាគមន៍កម្ពុជា(TRC) នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ជំរុញប្រតិបត្តិករផ្នែកសេវាកម្មទូរគមនាគមន៍ មានដូចជាក្រុមហ៊ុន៖ (១)ស្មាតអាស្យាតា ខូអិលធីឌី (២)ខេម ជីអេសអេម អែលធីឌី (៣)សៅអ៊ីស្ត អេស៊ា ធេលីខម ខេមបូឌា (៤)វៀតធេល ខេមបូឌា ផ្ញើការផ្ញើសារ(SMS) អបអរសាទរទិវាកុមារអន្តរជាតិ ១ មិថុនា ឆ្នាំ២០២១ ដែលមានខ្លឹមសារថា "យើងប្តេជ្ញាចិត្តរួមគ្នាលុបបំបាត់អំពើហិង្សាលើកុមារ និងអំពើរំលោភបំពានគ្រប់រូបភាពលើកុមារ" ជូនដល់ប្រជាពលរដ្ឋដែលកំពុងប្រើប្រាស់សេវាកម្មទូរគមនាគមន៍ បានចំនួន ៣,៨លានសារ។
  - បានផ្សព្វផ្សាយច្បាប់ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ តាមរយៈផេកហ្វេសប៊ុក បានចំនួន ៥មាត្រា ដែលមានអ្នកឃើញចំនួន ៤.០១៥នាក់។
- **ខេត្តសៀមរាប៖** មន្ទីរព័ត៌មាន បានធ្វើការផ្សព្វផ្សាយអប់រំ នៅក្នុងកម្មវិធីវិទ្យុជាតិនគរភ្នំ FM១០៣MHz និងទូរទស្សន៍ជាតិខេត្តសៀមរាប ស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងការជួញដូរមនុស្ស ចំនួន **៥៤**លើក (ផ្សាយផ្ទាល់**១៨**លើក និងចាក់ផ្សាយឡើងវិញ**៣៦**លើក)។
- **ខេត្តមណ្ឌលគិរី៖** មន្ទីរធម្មការ និងសាសនាខេត្ត បានធ្វើការផ្សព្វផ្សាយបញ្ជ្រាប តាមវិទ្យុ FM៩៧MHz ក្នុងកម្មវិធី ព្រះពុទ្ធសាសនាផ្សារភ្ជាប់សង្គម ចំនួន **២០**ថ្ងៃក្នុង១ខែ។

២.១.៣. ការចូលរួមជាវាគ្មិន ក្នុងកម្មវិធីនានា

- **ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖** ឯកឧត្តម ឧត្តមសេនីយ៍ទោ **កែវ សុវណ្ណារ៉ា** អគ្គលេខាធិការរងគ.ជ.ប.ជ និងលោកអនុសេនីយ៍ឯក **ហង្ស ពុទ្ធាវិទ្ធិ** បានចូលរួមធ្វើជាគ្រូឧទ្ទេសជាមួយក្រុមគ្រូឧទ្ទេសថ្នាក់ជាតិក្រសួងអប់រំ យុវជន និងកីឡា ដែលដឹកនាំដោយ លោកជំទាវ **សឿ សុជាតា** អនុរដ្ឋលេខាធិការ ក្នុងវគ្គសិក្ខាសាលាបំប៉ន ស្តីពីការប្រើប្រាស់សៀវភៅអប់រំ ស្តីពីការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស និងលំនាំនៃការបង្រៀន ជូនលោកគ្រូអ្នកគ្រូនៅខេត្តកំពង់ឆ្នាំង តាមប្រព័ន្ធហ្សូម(zoom)។
- **ខេត្តសៀមរាប៖** ស្នងការដ្ឋាននគរបាលខេត្ត បានចូលរួមជាវាគ្មិននៅប៉ុស្តិ៍វិទ្យុ ទូរទស្សន៍ជាតិខេត្ត ក្នុងកម្មវិធីយើង ធ្វើបាន ក្រោមប្រធានបទ ស្តីពីការបង្ការ ទប់ស្កាត់ការរំលោភសេពសន្ថវៈលើស្ត្រី និងកុមារ ការលើកទឹកចិត្តឱ្យមាន មន្ត្រីនគរបាលជាស្ត្រី នៅតាមមូលដ្ឋាន និងការលើកកម្ពស់ការយល់ដឹងរបស់ស្ត្រីពីការជួញដូរផ្លូវភេទ ០៣លើក។
- **ខេត្តកំពង់ចាម៖** បានចូលរួមជាវាគ្មិនក្នុងកម្មវិធីសន្ទាមតិ ដើម្បីផ្សព្វផ្សាយ តាមរយៈវិទ្យុជាតិ នៃមន្ទីរព័ត៌មានខេត្ត និងផ្សព្វផ្សាយតាមបណ្តាញសង្គម ហ្វេកប៊ុក លើប្រធានបទ (រួមគ្នាលុបបំបាត់ និងទប់ស្កាត់ការជួញដូរស្ត្រី និងកុមារ និងវិធានការទប់ស្កាត់ជំងឺកូវីដ១៩ របស់ក្រសួងសុខាភិបាល ដល់ពលចំណូលស្រុក ០២លើក។
- **ខេត្តបាត់ដំបង៖** បានចូលរួមជាវាគ្មិនក្នុងកិច្ចពិភាក្សា ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងផលប៉ះពាល់ ពីការធ្វើចំណាកស្រុកដោយខុសច្បាប់ នៅវិទ្យុជាតិចំការចេក 92.70MHz ០១លើក និងការទប់ស្កាត់ការរំលោភបំពានសិទ្ធិ និងការកេងប្រវ័ញ្ចពលកម្មកុមារ ០១លើក។

២.២. ការផ្សព្វផ្សាយតាមរយៈឧបករណ៍(IEC)

- **ខេត្តបន្ទាយមានជ័យ៖ អង្គការសាម៉ារីតាន់ភឺស** ផ្តល់ការអប់រំ និងចែកប័ណ្ណផ្សព្វផ្សាយអំពីការធ្វើចំណាកស្រុកដោយសុវត្ថិភាពសរុបមានចំនួន **៧២៦**នាក់(ស្ត្រី **២៥១**នាក់) កុមារ **៨៥**នាក់ កុមារី **៣៦**នាក់)។
- **ខេត្តបាត់ដំបង៖ អង្គការការីតាស់** បានផ្តល់ខិត្តប័ណ្ណផ្សព្វផ្សាយ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដល់ពលករចំនួន **១.០៩៦**នាក់។

ខ.៣. ការបង្ការ ទប់ស្កាត់តាមវិធានការជំនាញ

**ខ.៣.១. ការគ្រប់គ្រងស្ថិតិ៖ បច្ចុប្បន្នភាពចំណាកស្រុក**

- **អគ្គស្នងការដ្ឋាននគរបាលជាតិ**

- ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត បានធ្វើបច្ចុប្បន្នភាពទិន្នន័យប្រចាំខែ ចំពោះពលករចំណាកស្រុក ត្រឡប់មកពីក្រៅប្រទេសវិញ ទាំងស្របច្បាប់ និងមិនស្របច្បាប់ សរុបចំនួន ១៥០.៨៨៥នាក់ (ស្រី ៥៤.៥៥៦នាក់) អនីតិជន ៥៦៤នាក់(ស្រី ១៥៦នាក់)។

- **ខេត្តបាត់ដំបង៖** កម្លាំងល្បាតតាមបន្ទាត់ព្រំដែន របស់វរៈនគរបាលការពារព្រំដែនគោក វរសេនាតូចលេខ ៨១៧,៨១៩,៨២៣ និង៣១០ បានចេញល្បាតតាមបន្ទាត់ព្រំដែនភូមិសាស្ត្ររបស់ខ្លួន ចំនួន ១០លើក បានប្រទះឃើញពលករឆ្លងដែនខុសច្បាប់ចំនួន ៣៨នាក់ (ស្រី ២០នាក់) អនីតិជន ១១នាក់ បានធ្វើការអប់រំ និងឱ្យត្រឡប់ទៅលំនៅដ្ឋានវិញ។

- កម្លាំងជំនាញ នៃស្នងការដ្ឋាននគរបាលខេត្តចំនួន០៣ បានធ្វើការងារបង្ការ ទប់ស្កាត់ពលរដ្ឋខ្មែរ ដែលធ្វើចំណាកស្រុកទៅប្រទេសថៃ ដោយខុសច្បាប់បានចំនួន ៣១លើក មនុស្សចំនួន ២៨១នាក់ (ស្រី ១៣១នាក់) អនីតិជន១១នាក់ ក្នុងនោះមាន៖
  - ខេត្តបាត់ដំបង ចំនួន១០លើក មនុស្សចំនួន៣៨នាក់ (ស្រី២០នាក់) អនីតិជន១១នាក់។
  - ខេត្តបន្ទាយមានជ័យ ចំនួន១៨លើក មនុស្សចំនួន២១៥នាក់(ស្រី១០១នាក់)។
  - ខេត្តតាកែវ ចំនួន០៣លើក មនុស្សចំនួន២៨នាក់(ស្រី១០នាក់) និងបានធ្វើកិច្ចសន្យា អប់រំ ណែនាំកុំឱ្យធ្វើចំណាកស្រុកខុសច្បាប់ទៅក្រៅប្រទេសទៀត។

**ខ.៣.២. វិធានការបង្ការ ទប់ស្កាត់ តាមជំនាញគ្រប់គ្រងគោលដៅសង្ស័យបម្រើសេវាកម្មផ្លូវភេទ**

- **អគ្គស្នងការដ្ឋាននគរបាលជាតិ**

- កម្លាំងជំនាញ នៃស្នងការដ្ឋាននគរបាលខេត្តក្រចេះ ស្ទឹងត្រែង និងខេត្តព្រៃវែង បានល្បាតឃ្លាំមើល គោលដៅសង្ស័យមានសកម្មភាពអាជីវកម្មផ្លូវភេទ ចំនួន ១០លើក។

- **ខេត្តសៀមរាប៖** មន្ទីរទេសចរណ៍ខេត្ត បានចុះត្រួតពិនិត្យមូលដ្ឋានអាជីវកម្ម មណ្ឌលកម្សាន្តស្រាប់មនុស្សពេញវ័យ ស្តីពីការហាមប្រាមអនីតិជនចូលកម្សាន្ត កន្លែងអាជីវកម្មស្នាក់នៅ ជីវកម្មម៉ាស្សា អាជីវកម្មភោជនីយដ្ឋាន និងមូកដ្ឋានឌីស្កូតែក និងបានធ្វើការណែនាំអំពីវិធានការការទប់ស្កាត់ ការរីករាលដាលជំងឺកូវីដ១៩ របស់ក្រសួងសុខាភិបាល ចំនួន ០៦លើក មនុស្សចំនួន ៨៦នាក់ (ស្រី ៧៨នាក់)។

**ខ.៣.៣. ការបង្ការ ទប់ស្កាត់ ការជួញដូរមនុស្សតាមរយៈការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស**

- **ក្រសួងមហាផ្ទៃ**

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ (ក្រុមការងារអនុវត្តន៍ច្បាប់) បានធ្វើសម្ភាសន៍ពលរដ្ឋខ្មែរ និងជនបរទេសដែលបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ចំនួន ៤២គូ ដែលបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ និងបានប្រមូលព័ត៌មានពីសុខទុក្ខនារីខែដែលរៀបការ ទៅរស់នៅក្រៅប្រទេសតាមរយៈការទំនាក់ទំនងតាមទូរស័ព្ទចំនួន ១៣នាក់(ប្រទេសកូរ៉េខាងត្បូង) មានសេចក្តីសុខសប្បាយជាធម្មតា។

**ខ.៤. កិច្ចការពារកុមារ ពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ**

- **ខេត្តព្រះសីហនុ៖** បន្តសហការជាមួយអង្គការម្លប់តាប៉ាង ធ្វើការទំនាក់ទំនងជាប្រចាំជាមួយបណ្តាញ ដែលបានដាក់ចំនួន ១.១៣៣នាក់ (ម៉ូតូឌុប ក្រុមម៉ូតូកង់បី ផ្ទះសំណាក់ សណ្ឋាគារ អ្នកលក់តាមឆ្នេរសមុទ្រ ភ្នាក់ងារទេសចរណ៍ និងសហគមន៍) ដើម្បីទប់ស្កាត់ទេសចរណ៍ផ្លូវភេទលើកុមារ។

- **ខេត្តសៀមរាប៖** មន្ទីរទេសចរណ៍ខេត្ត បានចុះផ្សព្វផ្សាយច្បាប់ ស្តីពីទេសចរណ៍ សេវាកម្មទេសចរណ៍ តាមមូលដ្ឋានអាជីវកម្ម និងបញ្ជ្រាបអំពីការទប់ស្កាត់ការជួញដូរមនុស្ស និងការរំលោភបំពានផ្លូវភេទ

លើកុមារ និងធ្វើការណែនាំអំពីវិធានការទប់ស្កាត់ការរីករាលដាលជំងឺកូវីដ១៩ ចំនួន ២៥លើក មនុស្ស ចំនួន ១៩២នាក់ (ស្រី ១៧៥នាក់)។

- ខេត្តប៉ៃលិនៈ បានចុះអធិការកិច្ចដើម្បីទប់ស្កាត់ និងលុបបំបាត់នូវទម្រង់ជួញដូរដ៏ធ្ងន់ធ្ងរលើពលកម្មកុមារ នៅតាមសហគ្រាស គ្រឹះស្ថានដែលមានការប្រើប្រាស់កម្លាំងពលកម្មដូចជា សៃឡ កាស៊ីណូ ឡឥដ្ឋ ភោជនីយដ្ឋាន និងអាហារដ្ឋាន ចំនួន ៨០កន្លែង ជាលទ្ធផលរកពុំឃើញមានជួញដូរកម្លាំងពលកម្មកុមារទេ។
- ខេត្តក្រចេះ៖

-មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានចុះធ្វើអធិការកិច្ចលើការថែទាំជំនួសចំពោះកុមារ នៅមណ្ឌលអង្គការដំណឹងល្អទាំងបួន និងភូមិកុមារកម្ពុជា SOS ខេត្តក្រចេះ ចំនួន ០២លើក។

-មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្របច្ចេកវិទ្យា និងនវានុវត្តន៍ បានចុះផ្សព្វផ្សាយអំពីខ្លឹមសារ ការកេងប្រវ័ញ្ចលើពលកម្មកុមារ ការទប់ស្កាត់រាល់សកម្មភាពជួញដូរ និងប្រើអំពើហិង្សាលើបុគ្គលិកកម្មករ(ពិសេសកុមារ) តាមបណ្ដាសិប្បកម្មស្រាល នៅស្រុកព្រែកប្រសព្វ បានចំនួន០៦មូលដ្ឋាន មានបុគ្គលិកចំនួន ២០នាក់ (ស្រី ០៥នាក់)។

## គ. ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស

### គ.១. ការងារអនុវត្តច្បាប់

លទ្ធផលបង្ក្រាបបទល្មើសអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ខាងក្រោមនេះទទួលបានពីនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត។

#### គ.១.១. ការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ

អគ្គស្នងការដ្ឋាននគរបាលជាតិ កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត បានតាមដានស្រាវជ្រាវ បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ សរុបបាន ២៥ករណី(ធៀបនឹងខែឧសភា មានចំនួន ៤០ករណី ថយចុះចំនួន ១៥ករណី)ស្មើនឹង៣,៥% ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូងចំនួន ៣៧នាក់ (ស្រី ០៥នាក់) នជនបរទេសចំនួន ០១នាក់ (សញ្ជាតិបែលហ្សិច)។

សង្គ្រោះជនរងគ្រោះ ចំនួន ៩៨នាក់ មានៈ អាយុក្រោម១៥ឆ្នាំ ១៦នាក់ អាយុ១៥-១៧ឆ្នាំ ១២នាក់ និងអាយុពី១៨ឆ្នាំឡើង ៧០នាក់ (ប្រគល់ឱ្យគ្រួសារ ៩៨នាក់) ក្នុងនោះចែកជា៖

១. ករណីអំពើជួញដូរមនុស្ស

បង្ក្រាបបាន ១៤ករណី/៣១ករណី (កើនឡើង ០២ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន ១១នាក់ (ស្រី ០២នាក់) ជនបរទេសសញ្ជាតិបែលស៊្សិច ០១នាក់។ សង្គ្រោះជនរងគ្រោះចំនួន ៨២នាក់ មានៈ អាយុក្រោម១៥ឆ្នាំ ០៤នាក់ អាយុ១៥-១៧ឆ្នាំ ០៨នាក់ និងអាយុ១៨ឆ្នាំឡើង ៧០នាក់ (ប្រគល់ឱ្យគ្រួសារ ៨២នាក់)។

*តារាងស្ថិតិបទល្មើសជួញដូរមនុស្ស*

| បទល្មើស | ករណី | ជនរងគ្រោះ | ជនសង្ស័យ | ជនបរទេស |
|---|---|---|---|---|
| -ការនាំយកអនីតិជនជាអាទិ៍ចេញដោយមិនស្របច្បាប់ | ០១ | ០២ | ០២ | |
| -ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន | ១១ | ៧៤ | ២២ | |
| -ការទទួលយកមនុស្សដោយមានគោលដៅជួយដល់ជនល្មើស | ០១ | ០៣ | ០១ | |
| -ការទិញពេស្យាចារកុមារ | ០១ | ០៣ | ០១ | បែលស៊្សិច១ |
| *សរុប* | *១៤ ករណី* | *៨២ នាក់* | *២៦ នាក់* | *០១ នាក់* |

២. ករណីអំពើធ្វើអាជីវកម្មផ្លូវភេទ

បង្ក្រាបបាន ១១ករណី/០៩ករណី (កើនឡើង ០២ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន ១១នាក់ (ស្រី ០២នាក់)។ សង្គ្រោះជនរងគ្រោះចំនួន ១៦នាក់ មានៈ អាយុក្រោម១៥ឆ្នាំ ១២នាក់ អាយុ១៥-១៧ឆ្នាំ ០៤នាក់ (ប្រគល់ឱ្យគ្រួសារ ១៦នាក់)។

*តារាងស្ថិតិបទល្មើសអាជីវកម្មផ្លូវភេទ*

| បទល្មើស | ករណី | ជនរងគ្រោះ | ជនសង្ស័យ |
|---|---|---|---|
| -សញ្ញារកម្ម | ០១ | គ្មាន | ០១ |
| -សញ្ញារកម្មទាក់ទងនឹងពេស្យាចារកុមារ | ០១ | ០៤ | ០១ |
| -អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ | ០៧ | ០៧ | ០៧ |
| -អំពើអាសអាភាសប្រឆាំងនឹងអនីតិជនអាយុក្រោម១៥ឆ្នាំ | ០២ | ០៥ | ០២ |
| *សរុប* | *១១ ករណី* | *១៦ នាក់* | *១១ នាក់* |

## ឃ. កិច្ចការពារជនរងគ្រោះ និងការផ្តល់សេវាគាំទ្រ

### ឃ.១. ការទទួល និងសម្ភាសន៍ពលករបញ្ជូនត្រឡប់តាមច្រកព្រំដែន (ផ្លូវគោក និង ផ្លូវអាកាស) ដើម្បីកំណត់មុខសញ្ញាជនរងគ្រោះ

#### ឃ.១.១. ការទទួល និងសម្ភាសពលករបញ្ជូនត្រឡប់

▪ អគ្គស្នងការដ្ឋាននគរបាលជាតិ

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានទទួល និងសម្ភាសន៍ជនរងគ្រោះ ដែលបានវិលត្រឡប់មកពីក្រៅប្រទេសតាមរយៈអនឡាញ ចំនួន ២៩នាក់(ស្រី) ក្នុងនោះមានប្រទេសចិន ចំនួន ២៨នាក់ និងប្រទេសសឹង្ហបុរីចំនួន ០១នាក់ ជាលទ្ធផល ជនរងគ្រោះទៅតាមរយៈមេខ្យល់មិនស្គាល់អត្តសញ្ញាណចំនួន ២៨នាក់(ចិន) និងទៅតាមរយៈក្រុមហ៊ុន ០១នាក់(សឹង្ហបុរី)។

▪ **ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត**

• **ស្នងការដ្ឋាននគរបាលខេត្តចំនួន០២** បានទទួល និងសម្ភាសពលករខ្មែរ ដែលអាជ្ញាធរបរទេសចាប់បញ្ជូនត្រឡប់មកកម្ពុជាវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិកម្ពុជា-ថៃ និងច្រកទ្វារព្រំដែនអន្តរជាតិ កម្ពុជា-វៀតណាម ចំនួន ៤៥លើក មនុស្សចំនួន ១.០០៣នាក់(ស្រី ១៣៤នាក់ អនីតិជន ០១នាក់) ក្នុងនោះមាន៖

- ខេត្តព្រះវិហារ ចំនួន ០៣លើក មនុស្សចំនួន ០៤នាក់ (ស្រី ០២នាក់)។
- ខេត្តកោះកុង ចំនួន ១៣លើក មនុស្សចំនួន ២៨នាក់ (ស្រី ០៩នាក់) អនីតិជន ០១នាក់។

• **ខេត្តបន្ទាយមានជ័យ៖** ក្រុមការងារបានទទួល នឹងសម្ភាសន៍ជនទេសន្តរប្រវេសន៍(ពលរដ្ឋខ្មែរ) ដែលអាជ្ញាធរថៃបញ្ជូនតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត ច្រកអូរបីជាន់ និងច្រកម៉ាឡៃ ប្រចាំខែមិថុនា ឆ្នាំ២០២១ មានពលករសរុបចំនួន៖ ៤.០០៥នាក់(ស្ត្រី ១.៦៤១នាក់) អនីតិជន ៥០២នាក់។

## III. ការលើកកម្ពស់សមត្ថភាព និងការសម្របសម្រួល

### ក. ការបណ្តុះបណ្តាល និងសិក្ខាសាលា

#### ក.១. ការងារបណ្តុះបណ្តាល

- ខេត្តសៀមរាប បានសហការជាមួយអង្គការបន្ទាយស្រី រៀបចំវគ្គបណ្តុះបណ្តាលតាមប្រព័ន្ធវីដេអូចំនួន ០២លើក៖ (១)ស្តីពីការទប់ស្កាត់ការធ្វើចំណាកស្រុកខុសច្បាប់ និងកិច្ចការពារកុមារនៅ សហគមន៍ ដល់រដ្ឋបាលឃុំចំនួន០៦ និងរដ្ឋបាលឃុំស្រុកអង្គរជុំ អ្នកចូលរួមចំនួន ១៥នាក់ (ស្រី ០៨នាក់)។ (២)ស្តីពីការពង្រឹងសមត្ថភាពលើការកត់ត្រាទិន្នន័យពលករចំណាកស្រុមក និងការវិលត្រឡប់ពីការក្រៅប្រទេស អ្នកចូលរួមចំនួន ១០នាក់ (ស្រី ០៣នាក់)។

**ក.២. ការងារសិក្ខាសាលា**

- ក្រសួងអប់រំ យុវជន និងកីឡា សហការជាមួយអង្គការភ្លែន និងក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ រៀបចំសិក្ខាសាលាវគ្គបំប៉ន ស្តីពីការប្រើប្រាស់សៀវភៅអប់រំ ស្តីពីការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស និងលំនាំនៃការបង្រៀន តាមប្រព័ន្ធហ្សូម(zoom) ជូនដល់លោកគ្រូអ្នកគ្រូនៅខេត្តកំពង់ឆ្នាំង ចំនួន ៥៣នាក់ (ស្រី ៣០នាក់)។

**ខ. សន្និសីទ កិច្ចប្រជុំ ទស្សនកិច្ច និងជំនួបពិភាក្សាការងារ**

**ខ.១. ក្នុងប្រជុំក្នុងប្រទេស និងក្រៅប្រទេស**

- គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)
  - លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញជាអធិបតីភាពដឹកនាំកិច្ចប្រជុំ៖
    - ជាមួយរដ្ឋបាលស្រុកកំរៀង ស្តីពី ការពិនិត្យស្ថានភាពលំហូរ ឆ្លងកាត់ព្រំដែន និងផែនការសកម្មភាពជាអាទិភាព ក្នុងការដាក់ឱ្យដំណើរការការងារ នៅក្នុងមណ្ឌលទទួលពលករកំរៀង ដោយមានការចូលរួមពី**លោកជំទាវ ប៉ុណ្ណ សំខាន់** អគ្គលេខាធិការ ឯកឧត្តម ឧត្តមសេនីយ៍ឯក **យ៉ែម ចាន់ណារ៉ុ** អគ្គលេខាធិការរង និងលោកស្រីអភិបាលរងខេត្តបាត់ដំបង លោកអភិបាល អភិបាលរងស្រុកកំរៀង ប្រធាន និងសហការីអង្គការការីតាសស្វីស អធិការនគរបាលស្រុក ប្រធានប៉ុស្តិ៍នគរបាលច្រកព្រំដែនអន្តរជាតិដូង មេបញ្ជាការយោធាសីករងស្រុក តំណាងពីមន្ទីរសុខាភិបាល មន្ទីរសង្គមកិច្ច មន្ទីរការងារ និងមន្ត្រីសាលាស្រុកកំរៀង នៅសាលប្រជុំសាលាស្រុកកំរៀង។
    - តាមប្រព័ន្ធវីដេអូអនឡាញ ស្តីពីគោលការណ៍មិនដាក់ទណ្ឌកម្មលើជនរងគ្រោះ ដោយអំពើជួញដូរ ដោយមានការអញ្ជើញចូលរួមពី ឯកឧត្តម **ហូ វុឌ្ឍី** រដ្ឋលេខាធិការក្រសួងការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ **លោកជំទាវ ប៉ុណ្ណ សំខាន់** អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានគ.ជ.ប.ជ ឯកឧត្តម **ប៉ែន ពេជ្យសាលី** អគ្គនាយក នៃអគ្គនាយកដ្ឋានកិច្ចការអយ្យការ និងព្រហ្មទណ្ឌ ឯកឧត្តម ឧត្តមសេនីយ៍ឯក **ជីវ ផល្លី** ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជននៃអគ្គស្នងការដ្ឋាននគរបាលជាតិ តំណាងពីក្រសួងសង្គមកិច្ច តំណាងពីក្រសួងការបរទេស ឯកឧត្តម ជាអគ្គលេខាធិការរង ទទួលបន្ទុកជួយជនរងគ្រោះ ការងាររដ្ឋបាល ការងារអនុវត្តច្បាប់ និងកិច្ចការងារយុត្តិធម៌ ឯកឧត្តម ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ តំណាងពីក្រសួងកិច្ចការនារី ប្រធានលេខាធិការដ្ឋាន គ.ជ.ប.ជ ប្រធានក្រុមជំនួយកិច្ចការ និងមន្ត្រីជំនាញពាក់ព័ន្ធនៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។
    - ពិគ្រោះយោបល់តុមូល តាមប្រព័ន្ធវីដេអូអនឡាញ «ស្តីពីគោលការណ៍មិនដាក់ទណ្ឌកម្មលើជនរងគ្រោះដោយអំពើជួញដូរ» ដោយមានការអញ្ជើញចូលរួមពីឯកឧត្តម **ហ៊ូ វុឌ្ឍី** រដ្ឋលេខាធិការក្រសួងការងារបណ្តុះបណ្តាលវិជ្ជាជីវៈ លោកជំទាវអគ្គលេខាធិការ គ.ជ.ប.ជ ឯកឧត្តម លោកជំទាវអគ្គលេខាធិការរង ប្រធានលេខាធិការដ្ឋាន នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ឯកឧត្តម អគ្គនាយកនៃនាយកដ្ឋានអយ្យការ និងកិច្ចការព្រហ្មទណ្ឌ ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស ការពារអនីតិជន អគ្គនាយករងនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ តំណាងក្រសួងសង្គមកិច្ច ជាប្រធាននាយកដ្ឋានប្រឆាំងការជួញដូរ សមាហរណកម្មជនរងគ្រោះ តំណាងក្រសួងកិច្ចការនារី ជាប្រធាននាយកដ្ឋាន ប្រធាននាយកដ្ឋាននីតិកម្មនៃក្រសួងអប់រំយុវជន និងកីឡាអ្នកសម្របសម្រួលគម្រោង AATIP គម្រោងអាស៊ាន អូស្ត្រាលីជាតំណាងចូលរួម និងតំណាងពីអង្គការដៃគូពាក់ព័ន្ធ។ AATIP

○ស្ដីពីផែនការសកម្មភាពការងារជាអាទិភាពត្រូវអនុវត្ត និងអំពីរបៀបរបបការងារប្រចាំថ្ងៃរបស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ដោយមានការអញ្ជើញចូលរួមពីលោកជំទាវ **ប៉ុណ្ណ សំខាន់**អគ្គលេខាធិការ គ.ជ.ប.ជ ឯកឧត្តម លោកជំទាវ អគ្គលេខាធិការរង និងប្រធានក្រុមជំនួយកិច្ចការ០៦ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ នៅបន្ទប់ប្រជុំអគ្គលេខាធិការដ្ឋាន។

○ស្ដីពីផែនការសកម្មភាពការងារជាអទិភាពត្រូវអនុវត្ត នៅធមាសទី២ ឆ្នាំ២០២១ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ដោយមានការអញ្ជើញចូលរួមពី លោកជំទាវ **ប៉ុណ្ណ សំខាន់** អគ្គលេខាធិការ ឯកឧត្តម លោកជំទាវ អគ្គលេខាធិការរង ប្រធានក្រុមជំនួយកិច្ចការនៃក្រុមជំនួយកិច្ចទាំង៦ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ នៅបន្ទប់ប្រជុំអគ្គលេខាធិការដ្ឋាន។

○ជាមួយអង្គការអាស៊ានអាក់ តាមប្រព័ន្ធវីដេអូអនឡាញ ស្ដីពីកិច្ចសហការណ៍ រវាង គ.ជ.ប.ជ និងអង្គការអាស៊ានអាក់ (ASIAN-ACT) ដោយមានការចូលរួមពី លោកជំទាវ **ប៉ុណ្ណ សំខាន់** អគ្គលេខាធិការ ឯកឧត្តម លោកជំទាវ អគ្គលេខាធិការរង និងទីប្រឹក្សាអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។

○រវាងថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ មន្ត្រីប្រចាំជូនមណ្ឌលទទួលពលករស្រុកកំរៀង ស្ដីពីរបៀបរបបការងារ នៃការប្រព្រឹត្តិទៅរបស់មណ្ឌលទទួលពលករ និងការប្រគល់ទទួល សម្ភារៈបច្ចេកទេស ជូនបុគ្គលិក និងមន្ត្រីប្រចាំជូនមណ្ឌលទទួលពលករស្រុកកំរៀង ដោយមានការចូលរួមពីលោកអភិបាលស្រុកកំរៀង លោកជំទាវ អគ្គលេខាធិការ គ.ជ.ប.ជ អគ្គលេខាធិការរងប្រធានក្រុមការងារព័ត៌មានវិទ្យានៃ គ.ជ.ប.ជ លោកស្រីអភិបាលរងខេត្តបាត់ដំបង ស្នងការងនគរបាលខេត្តសហការីរបស់អង្គការការីតាសស្វីស មន្ត្រីតំណាងពីមន្ទីការងារ មន្ទីរសង្គមកិច្ច និងមន្ត្រីសាលាស្រុកកំរៀង ។

## ១.២. ការទទួលជួបពិភាក្សាការងារ

▪ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)

- លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានទទួលជួបពិភាក្សាការងារ ជាមួយ៖

○ប្រធានអង្គការការីតាស់ស្វីស និងសហការី ស្ដីពីផែនការសកម្មភាពជាអាទិភាព ក្នុងការដាក់ឱ្យដំណើរការការងារនៅក្នុងមណ្ឌលទទួលពលករកំរៀង ស្ថិតក្នុងស្រុកកំរៀងខេត្តបាត់ដំបង។ និងមានការអមដំណើរដោយលោកជំទាវ ឧត្តមសេនីយ៍ឯក **ប៉ុណ្ណសំខាន់** និងឯកឧត្តម ឧត្តមសេនីយ៍ឯក **យ៉ែម ចាន់ណារុំ** អគ្គលេខាធិការ អគ្គលេខាធិការរង គ.ជ.ប.ជ ។

○ អនុប្រធានអចិន្ត្រៃលោកស្រីគ្រីស្ទីន ផាកូ ប្រធានអង្គការអាយអូអឹម IOM ប្រចាំប្រទេសកម្ពុជា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងរួមនិងសហការី ពិភាក្សាអំពីកិច្ចសហការជាមួយ គ.ជ.ប.ជ ពាក់ព័ន្ធលើកិច្ចការទេសន្តប្រវេសន៍ និងគម្រោងត្រៀមកិច្ចប្រជុំបន្តស្ដីពីកតិកាសញ្ញាពិភពលោកស្ដីពីទេសន្តប្រវេសន៍ដោយសុវត្ថិភាព និងរៀបរយ (GCM) ជាពិសេសគម្រោងផែនការអនុវត្តបន្តការងារមួយចំនួនទៀត នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។

○តំណាងស្ថានទូតសហរដ្ឋអាមេរិច និងទីប្រឹក្សារបស់ស្ថានទូត និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ស្ដីពីវឌ្ឍនភាពកិច្ចការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដោយមានការចូលរួមពីលោកជំទាវ **ប៉ុណ្ណ សំខាន់** អគ្គលេខាធិការ ឯកឧត្តមអគ្គលេខាធិការរង អនុប្រធានលេខាធិការដ្ឋាន នៃអគ្គលេខាធិការដ្ឋានគ.ជ.ប.ជ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។

▪ **ខេត្តសៀមរាប៖** លេខាធិការដ្ឋាន គ.ខ.ប.ជ ជំនួបពិភាក្សាការងារជាមួយអង្គការដៃគូចំនួន ០៤លើក៖

o អង្គការដែនដីមនុស្សហូរឡង់ដ៏ប្រចាំកម្ពុជា ស្តីពីការបញ្ចប់គម្រោងធ្វើការរួមគ្នាដើម្បីកុមារ(WATCH) និងពិភាក្សាលើការអនុវត្តគម្រោងថ្មីលើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងការផ្តល់នូវសម្ភារសម្រាប់ប្រើប្រាស់នៅក្នុងការិយាល័យចំនួន ០២លើក។

o អង្គការសម្ពន្ធភាពដើម្បីកុមារ លើករណីការកេងប្រវ័ញ្ចលើកុមារតាមប្រព័ន្ធអនឡាញ និងការផ្តល់សម្ភារសម្រាប់ការពារនៃការរីករាលដាលនៃជំងឺកូវីដ១៩ ចំនួន ០១លើក។

o ស្តីពីការអនុវត្តគម្រោងលើកម្ពស់ និងពង្រឹងអំណាចសេដ្ឋកិច្ចទៅលើវិស័យសេដ្ឋកិច្ចគ្រួសារ សម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ការកេងប្រវ័ញ្ចផ្លូវភេទ និងអំពើហិង្សាធ្ងន់ធ្ងរផ្នែក យេនឌ័រនៅក្នុងចំណោមពលករចំណាកស្រុកដែលបានវិលត្រឡប់មកកម្ពុជាវិញ តាមប្រព័ន្ធអនឡាញ ចំនួន ០១លើក។

### គ. ការងារសម្របសម្រួល

ការងាររៀបចំដឹកនាំសម្របសម្រួលកិច្ចប្រជុំ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅទូទាំងប្រទេសគឺ ១១៦លើក មានអ្នកចូលរួមសរុប ១.១១២នាក់ (ស្រី ៤៦២នាក់) ក្នុងនោះ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ៩៥លើក និងលេខាធិការដ្ឋានរាជធានី-ខេត្ត ចំនួន ២១លើក។ (**ឧបសម្ព័ន្ធ១**)

## IV. ការសន្និដ្ឋានវាយតម្លៃ

### ក.ចំណុចខ្លាំង

តាមរយៈការខិតខំប្រឹងប្រែង របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) សម្រេចការងារជាលទ្ធផលជោគជ័យគួរឱ្យកត់សម្គាល់៖

- ការគាំទ្ររបស់រាជរដ្ឋាភិបាល បានកំណត់យកបញ្ហាជួញដូរមនុស្សជាការងារសំខាន់ដែលត្រូវយកចិត្តទុកដាក់ និងផ្តល់អាទិភាពរកដំណោះស្រាយ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងថ្នាក់អន្តរជាតិផងដែរ។
- ការយកចិត្តទុកដាក់របស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់អនុសាសន៍ ០៤ចំណុច និងវិធានការ ០៦ចំណុច របស់សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាប្រធាន គ.ជ.ប.ជ គឺជាប្រទីបដ៏ល្អដល់គ.ជ.ប.ជ និងគ្រប់សមាសភាពដែលជាយន្តការក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- យើងមានច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ និងបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមូលដ្ឋានបង្អែក សម្រាប់ការអនុវត្តទប់ទល់ទៅនឹងបទល្មើសទាំងឡាយដែលកើតឡើង។
- យើងបានចុះសន្ធិសញ្ញា បត្យាប័ន អនុសញ្ញា អនុស្សរណៈនៃការយោគយល់គ្នា កិច្ចព្រមព្រៀង និងលិខិតបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមួយប្រទេសជិតខាងក្នុងតំបន់ និងសកលលោក លើវិស័យប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អំពើពេស្យាចារ រំលោភផ្លូវភេទ ជួញដូរស្ត្រី និងកុមារ...។ល។
- យើងមានយន្តការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលជាកម្លាំងស្នូលក្នុងការអនុវត្តការងារ។ ហើយតាមក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជន សុទ្ធតែបានចូលរួមយ៉ាងសកម្មក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើអសកម្មទាំងឡាយក្នុងសង្គមកម្ពុជា។
- ការកៀងគរកម្លាំង និងការជួយឧបត្ថម្ភពីអង្គការជាតិ អន្តរជាតិ វិស័យឯកជន និងថវិកាតាមក្រសួង ស្ថាប័ន អង្គភាពរៀបចំសម្រាប់ការអនុវត្តសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

### ខ. ចំណុចខ្វះខាត ឬភាពប្រឈម

ទន្ទឹមនឹងការខិតខំប្រឹងប្រែង យើងពិនិត្យឃើញនៅមានចំណុចប្រឈម និងសេសសល់មួយចំនួនដូចជា៖

- ក្រសួង ស្ថាប័ន អង្គភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សម្រាប់ជាយន្តការក្នុងការសហការ និងសហប្រតិបត្តិការគ្នា តែអង្គភាពមួយចំនួននៅមិនទាន់ចេះសហការគ្នាជាប្រព័ន្ធ និងបែងចែកការទទួលខុសត្រូវបន្តរហូតចប់ការងារ។
- ការធ្វើរបាយការណ៍នៅយឺតយ៉ាវ របាយការណ៍ភាគច្រើនមិនបានសម្រិតសម្រាំងឱ្យចេញពីសកម្មភាពអំពើជួញដូរមនុស្ស។
- មន្ត្រីយើងនៅមិនទាន់យល់ច្បាស់ពីប្រភេទការងារណា ដែលទាក់ទងនឹងអំពើជួញដូរមនុស្ស ដូចនេះពេលខ្លះយើងខ្វះអ្នកសហការ។

## គ. សំណូមពរ

- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការដៃគូត្រូវយកចិត្តទុកដាក់ទំនាក់ទំនង សហប្រតិបត្តិការ និងសាមគ្គីធ្វើការងារជាប្រព័ន្ធតាមជំនាញរៀងៗខ្លួន។
- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព និងអ្នកពាក់ព័ន្ធ ផ្តល់របាយការណ៍ឱ្យបានទៀងទាត់រាល់កិច្ចប្រជុំប្រចាំខែ របស់ក្រុមការងារអន្តរជំនាញ តាមវិស័យនីមួយៗ ដើម្បីប្រសិទ្ធភាពការងារ។
- ស្នើឱ្យលេខាធិការដ្ឋាន គ.រ.ប.ជ/គ.ខ.ប.ជ ផ្តល់របាយការណ៍ឱ្យបានទៀងទាត់ ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ។
- បើកវគ្គបណ្តុះបណ្តាលដល់មន្ត្រីទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ឲ្យយល់ពីការងារដែលទាក់ទងនឹងអំពើជួញដូរមនុស្ស តាមវិស័យនីមួយៗរបស់ខ្លួន។
- ស្នើសុំក្រសួង ស្ថាប័ន អង្គភាពទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ យកចិត្តទុកដាក់អនុវត្តតាមសេចក្តីសម្រេច ស្តីពីការតែងតាំងសមាសភាពក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលប្រធាន គ.ជ.ប.ជ បានសម្រេច។

## ឃ. សន្និដ្ឋាន

ការតាមដានត្រួតពិនិត្យ ត្រូវបានធ្វើឡើង ៖

- យើងមានការគាំទ្រ និងការយកចិត្តទុកដាក់ពីថ្នាក់ដឹកនាំ គ.ជ.ប.ជ និងរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា។ គោលនយោបាយល្អ និងការប្តេជ្ញាចិត្តខ្ពស់ មានឆន្ទៈមោះមុត មានសាមគ្គីភាព កិច្ចសហការប្រតិបត្តិការល្អ នោះយើងនឹងសម្រេចបាននូវលទ្ធផលជាទីគាប់ចិត្ត រួមកាត់បន្ថយបាននូវអំពើអសកម្មក្នុងសង្គម។
- ពីមួយថ្ងៃទៅមួយថ្ងៃមន្ត្រីយើងកាន់តែយល់ដឹង កាន់តែមានជំនាញ មានបទពិសោធន៍ ការងារកាន់តែស៊ីជម្រៅ ការទំនាក់ទំនងថ្នាក់ជាតិ និងអន្តរជាតិ កាន់តែច្រើន ធ្វើឱ្យយើងកាន់តែមើលឃើញនូវភាពខ្វះចន្លោះក្នុងកិច្ចការ និងមើលឃើញនូវតម្រូវការ ទាំងធនធានមនុស្ស សម្ភារ និងការចងក្រងលិខិតបទដ្ឋានគតិយុត្តនានា ដើម្បីសម្របសម្រួលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែមានប្រសិទ្ធភាព និងភាពរីកចម្រើន។
- បើយើងរៀបចំលកម្មភាព ផែនការអនុវត្ត និងផែនការយុទ្ធសាស្ត្របានល្អ យើងនឹងរៀបចំផែនការថវិកាកាន់តែប្រសើរសម្រាប់ការអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- ប្រសិនបើប្រជាពលរដ្ឋដែលជាអ្នកទទួលសេវាមានការយល់ដឹងច្រើន ពីអំពើជួញដូរមនុស្ស មានការប្រុងប្រយ័ត្ន មិនលង់តាមការណែនាំ បោកបញ្ឆោតពីពួកឱកាសនិយម និងបានចូលរួមសហការជាមួយអ្នកបម្រើសេវា នៃក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជននោះការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែទទួលបានជោគជ័យក្នុងសង្គមកម្ពុជាមិនខាន។

## V. ទិសដៅខែកក្កដា ឆ្នាំ ២០២១

ដើម្បីកែលម្អចំណុចខ្វះខាត និងពង្រឹងប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រទាំងបួន ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងរបៀបរបបការងារឱ្យកាន់តែល្អប្រសើរ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានដាក់ចេញនូវទិសដៅដូចខាងក្រោម ៖

១. បន្តពង្រឹងកិច្ចសហការទូលំទូលាយតាមរយៈ ការជួបប្រជុំពិភាក្សា បង្កើតសកម្មភាពផ្អែកលើយុទ្ធសាស្ត្ររួមដែលបានកំណត់ និងចូលរួមបែងចែកភារកិច្ច ពង្រាយកម្លាំង និងការទទួលខុសត្រូវ ឆ្ពោះទៅកាន់គោលដៅរួម គឺការបង្ការ ទប់ស្កាត់ ឈានទៅលុបបំបាត់អំពើជួញដូរមនុស្សគ្រប់រូបភាព។

២. ពង្រឹងប្រសិទ្ធភាពនៃការអនុវត្តវិធានការជាអាទិភាព ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ្រប់រូបភាពជាអាទិ៍៖ អំពើជួញដូរ និងកេងប្រវ័ញ្ចកម្លាំងពលកម្ម ជួញដូរផ្លូវភេទ ការដកហូតសរីរាង្គជួញដូរ ការរត់ពន្ធទារក និងកុមារឆ្លងដែន ការពពោះជំនួស និងការជួញដូរពលកម្ម ក្នុងឧស្សាហកម្មនេសាទសមុទ្រ...។

៣. ត្រៀមកិច្ចប្រជុំពិគ្រោះយោបល់រវាងក្រុមប្រទេសបញ្ជូន និងប្រទេសទទួល (ថៃ ម៉ាឡេស៊ី..) ដើម្បីពង្រឹងកិច្ចសហការ ចែករំលែកការទទួលខុសត្រូវ និងការពារផលប្រយោជន៍ពលករ ជាពិសេសពលករក្នុងឧស្សាហកម្មនេសាទ ព្រមទាំងនិយោជក រវាងប្រទេសបញ្ជូន និងប្រទេសទទួលប្រកបដោយសមធម៌។

៤. គាំទ្រ ពង្រឹងសមត្ថភាពជំនាញពាក់ព័ន្ធគ្រប់ផ្នែក ដល់មន្ត្រីជំនាញ ពង្រឹងការគ្រប់គ្រង របៀបរបបការងាររបស់ក្រុមការងារ និងលេខាធិការដ្ឋានរាជធានី-ខេត្ត។

៥. បន្តការងារផ្សព្វផ្សាយអប់រំតាមគ្រប់រូបភាព និងប្រើគ្រប់លទ្ធភាព និងធនធាន ដើម្បីលើកកម្ពស់ការយល់ដឹងជាសកល អំពីការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ទំនាក់ទំនងរវាងទេសន្តរប្រវេសន៍ និងអំពើជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធដទៃទៀត ឱ្យបានដល់ប្រជាពលរដ្ឋជាពិសេសស្រទាប់យុវវ័យ ក្នុងសាលារៀន និងក្រៅសាលារៀន និងជនដែលងាយរងគ្រោះ។

៦. បន្តរៀបចំសកម្មភាពបណ្តុះបណ្តាល មន្ត្រីពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណជនរងគ្រោះនៅតាមបណ្តាក្រសួង ស្ថាប័ន អង្គការដៃគូក្នុងស្រុក និងមន្ត្រីប្រចាំស្ថានទូតកម្ពុជា ក្នុងប្រទេសគោលដៅ ព្រមទាំងចុះតាមដានការអនុវត្ត។

៧. បន្តតាមដានលទ្ធផល និងប្រសិទ្ធភាពនៃការអនុវត្តកិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី និងគាំទ្រដល់ការអនុវត្តអនុសញ្ញាអាស៊ានប្រឆាំងការជួញដូរមនុស្សដែល **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានចុះហត្ថលេខារួមគ្នា កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៥។

៨. ជំរុញតាមដានត្រួតពិនិត្យក្រុមហ៊ុនបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេស ឱ្យអនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលឱ្យបានត្រឹមត្រូវ។

៩. បន្តរៀបចំវិធានការ "គ្រប់គ្រងលំហូរ ពលករទេសន្តរប្រវេសន៍ការងារឆ្លងដែនមិនប្រក្រតី" (គោរពតាមអនុសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ )។

១០. ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ជាពិសេសការពង្រឹងកិច្ចសហការក្នុងការជួយគ្នាទៅវិញទៅមក ក្នុងវិស័យយុត្តិធម៌ព្រហ្មទណ្ឌ ជាមួយប្រទេសពាក់ព័ន្ធ។

១១. បន្តអនុវត្ត និងចូលរួមយ៉ាងសកម្ម ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព របស់រាជរដ្ឋាភិបាល ។

១២. ជំរុញសាងសង់ជម្រកបណ្តោះអាសន្ន នៅតាមច្រកព្រំដែនសំខាន់ៗ ដែលមានការបញ្ជូនត្រឡប់ពីប្រទេសថៃនៅតែមានជាប់បន្ត ជារៀងរាល់ថ្ងៃ ដោយមានមន្ត្រីប្រចាំការ សម្រាប់ការផ្តល់សេវាចាំបាច់មួយចំនួន ដូច

ជាការពិនិត្យ ព្យាបាលសុខភាពបឋម អាហារ សម្រាប់មនុស្សចាស់ កុមារ ទារក ការស្នាក់នៅបណ្ដោះអាសន្ន មុនពេលចេញដំណើរ ការសាកសួរសុខទុក្ខ សម្របសម្រួល និងស្ដាប់សំណូមពរដើម្បីបន្តដោះស្រាយនៅនឹងកន្លែង ឬ នៅតាមបណ្ដាខេត្តប្រភពរបស់ពលករជាដើម។

ថ្ងៃ.អង្គារ ៩ កើត...ខែ.ស្រាពណ៍......ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី...១៧...ខែ...សីហា...ឆ្នាំ២០២១

**អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

ជួ ប៊ុនអេង

**ចម្លងជូន**

- ខុទ្ទកាល័យ សម្ដេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្ដេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ

**"ដើម្បីគោរពជូនជាសេចក្ដីរាយការណ៍"**

- ឯកឧត្ដម លោកជំទាវ ប្រធានក្រុមការងារជំនាញ អន្តរក្រសួង ស្ថាប័ន
- សមាជិកក្រុមការងារគ.ជ.ប.ជ
- អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

**"ដើម្បីជូនជ្រាប"**

- ឯកសារ កាលប្បវត្តិ

## ឧបសម្ព័ន្ធទី១

តារាងការងារដឹកនាំ និងសម្របសម្រួល កិច្ចសហប្រតិបត្តិការ (សរុបចំនួន ១១៦លើក) មនុស្សចំនួន ១.១១២នាក់ (ស្រី ៤៦២នាក់)

| ស្ថាប័ន<br>សម្របសម្រួល | សកម្មភាព |
|---|---|
| ណៈកម្មាធិការជាតិ<br>ប្រយុទ្ធប្រឆាំងអំពើ<br>ជួញដូរមនុស្ស<br>(គ.ជ.ប.ជ) | គណៈកម្មាធិការជាតិ គ.ខ.ប.ជ សម្របសម្រួលចំនួន ៩៥លើក អ្នកចូលរួមសរុបចំនួន ៦០២នាក់ (ស្រី ២៥៨នាក់)<br>▪ លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញ៖<br>- ក្នុងពិធីប្រគល់ទទួលសម្ភារៈការិយាល័យ មានតុ៥សម្រាប់ ជូនរដ្ឋបាលសាលាស្រុកកំរៀង ប្រើប្រាស់ក្នុងមណ្ឌលទទួលពលករកំរៀង ស្ថិតក្នុងឃុំបឹងរាំង ស្រុកកំរៀង ខេត្តបាត់ដំបង ដែលអមដំណើរដោយលោកជំទាវឧត្តមសេនីយ៍ឯក វេជ្ជ. ប៉ុណ្ណ សំខាន់ អគ្គលេខាធិការ ឯកឧត្តម ឧត្តមសេនីយ៍ឯក យ៉ែម ចាន់ណារុំ អគ្គលេខាធិការរង លោកស្រី ស៊ុំ ចិន្តាអភិបាលរងខេត្តបាត់ដំបង លោកស្រីស្នងការរងនគរបាលបាលខេត្ត លោក ទិត្យ សត្យាអភិបាលរងស្រុកកំរៀងតំណាងពីមន្ទីរពាក់ព័ន្ធ មានមន្ទីរការងារ មន្ទីរសង្គមកិច្ច មន្ត្រីរដ្ឋបាលស្រុកកំរៀង ប្រធាន និងតំណាងអង្គការការីតាសស្វីសនៅមណ្ឌលទទួលពលករកំរៀងខេត្តបាត់ដំបង។<br>- ដឹកនាំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ចូលរួមគោរពវិញ្ញាណក្ខន្ធ ឯកឧត្តមទេសរដ្ឋមន្ត្រី ត្រាំ អ៊ីវតឹក រដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ដែលបានធ្វើកាលកិរិយា ក្នុងជន្មាយុ៧៣ឆ្នាំ កាលពីថ្ងៃទី០១ ខែមិថុនា ឆ្នាំ ២០២១ វេលាម៉ោង១៤ និង២៥នាទី។<br>- ប្រគល់ និងទទួលសៀវភៅរបាយការណ៍លទ្ធផលសកម្មភាពការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០២០ និងទិសដៅអនុវត្តឆ្នាំ២០២១ របស់ គ.ជ.ប.ជ និងតំណាងអង្គការអាស៊ាន-អាក់ Asian-Act ដែលជាអ្នក ឧបត្ថម្ភគាំទ្រដល់ការបោះពុម្ពផ្សាយរបាយការណ៍នេះ និងមានការអញ្ជើញចូលរួមពី ឯកឧត្តមលោកជំទាវ អគ្គលេខាធិការរង ប្រធានលេខាធិការដ្ឋាន និងមន្ត្រីក្រោមឱវាទរបស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ។<br>- ដឹកនាំក្រុមការងារតាមដានត្រួតពិនិត្យ គោលនយោបាយរាជរដ្ឋាភិបាលខេត្តកំពង់ឆ្នាំង រួមនិងក្រុមការងារ លោកជំទាវ ប៉ុណ្ណ សំខាន់ អគ្គលេខាធិការ គ.ជ.ប.ជ លោកជំទាវ រ៉ែន ស៊ីលក្ខិណា អគ្គលេខាធិការរង ឯកឧត្តម យ៉ែម ចាន់ណារុំ អគ្គលេខាធិការរង បាននាំយកនូវអំណោយជាសម្ភារៈប្រើប្រាស់ សម្ភារៈប្រើប្រាស់ជាKit (កញ្ចប់) ចំនួន៥០ ដែលបានមកពីការឧបត្ថម្ភគាំទ្រអង្គការ UNFPA ផ្ដល់ជូនរដ្ឋបាលក្រុងកំពង់ឆ្នាំងដោយមានការចូលរួមពីថ្នាក់ដឹកនាំខេត្តមាន លោកអភិបាលរងក្រុង និងមន្ត្រីចំណុះរដ្ឋបាលខេត្តកំពង់ឆ្នាំង សម្រាប់ផ្ដល់ជូនពលករវិលត្រឡប់ និងប្រជាជនដែលកំពុងធ្វើចត្តាឡីស័ក ក្នុងអំឡុងពេលនៃការរាតត្បាតជំងឺកូវីដ-១៩ នៅក្រុងកំពង់ឆ្នាំង។ សម្ភារៈសម្រាប់ផ្ដល់ជូនបងប្អូនពលករ ក៏ដូចប្រជាពលរដ្ឋអាចទទួលបាន ក្នុងម្នាក់ៗទទួលបានមួយកញ្ចប់មាន៖ សារុំង១ ក្រម៉ា១ សាប៊ូម្សៅ សាប៊ូដុំ ដែលលាងដៃ ម៉ាស់មួយប្រអប់ សំឡីអនាម័យ ថ្នាំដុសធ្មេញ ច្រាស់ដុសធ្មេញ។<br>- ដឹកនាំតាមដានត្រួតពិនិត្យគោលនយោបាយ ភូមិ/ឃុំមានសុវត្ថិភាពខេត្តកំពង់ឆ្នាំងនិងថ្នាក់ដឹកនាំ របស់អគ្គលេខាធិការដ្ឋានគ.ជ.ប.ជមានលោកជំទាវ ប៉ុណ្ណ សំខាន់ អគ្គលេខាធីការលោកជំទាវ រ៉ែន សិរីលក្ខិណា អគ្គលេខាធិការរង ឯកឧត្តម យ៉ែម ចាន់ណារុំ អគ្គលេខាធិការរង បានអញ្ជើញចូលរួមគោរពវិញ្ញាណក្ខន្ធ ឧបាសិកា |

អ៊ុន គឹមសាន ត្រូវជាម្តាយបង្កើតឯកឧត្តម ហ៊ី ណាត ទីប្រឹក្សាក្រសួងមហាផ្ទៃ ដែលបានទទួលមរណៈកាលពីថ្ងៃអង្គារ ១៣កើត ខែបឋមសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥ វេលាម៉ោង១៥ និង២នាទីរសៀល ក្នុងជន្មាយុ ៩១ឆ្នាំ ដោយរោគាពាធ ដែលសពបានតំកល់ធ្វូលបុណ្យ នៅគេហដ្ឋានរបស់ឯកឧត្តម ឋិតក្នុងភូមិម៉ុងបារាំង សង្កាត់ប្អេរ ក្រុងកំពង់ឆ្នាំង។

▪ **អគ្គលេខាធិការដ្ឋានគ.ជ.ប.ជ** លោកជំទាវ ឧត្តមសេនីយ៍ឯក **ប៉ុណ្ណ សំខាន់** អគ្គលេខាធិការ គ.ជ.ប.ជ បានអញ្ជើញចូលរួមៈ

- កិច្ចពិភាក្សាជាមួយប្រធានអង្គការការីតាស់ស្វីស និងសហការី ស្តីពីផែនការសកម្មភាពជាអាទិភាពក្នុងការដាក់ឱ្យដំណើរការការងារ ប្រគល់ទទួលសម្ភារៈការិយាល័យជូនរដ្ឋបាលសាលាស្រុកកំរៀង ប្រើប្រាស់ក្នុងមណ្ឌលទទួលពលករកំរៀង ខេត្តបាត់ដំបង ។ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់លោកជំទាវ ជូ ប៊ុនអេង ជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ។ អញ្ជើញមានវត្តមានក្នុងពិធីមាន ឯកឧត្តម ឧត្តមសេនីយ៍ឯក **យ៉ែម ចាន់ណារុំ** អគ្គលេខាធិការរង គ.ជ.ប.ជ លោកស្រី **ស៊ុំ ចិន្តា** អភិបាលរងខេត្តបាត់ដំបង លោកស្រីស្នងការរងនគរបាលខេត្ត លោក ទិត្យ សត្យា អភិបាលរងស្រុកកំរៀង តំណាងពីមន្ទីរពាក់ព័ន្ធ មានមន្ទីរការងារ មន្ទីរសង្គមកិច្ច មន្ត្រីរដ្ឋបាលស្រុកកំរៀង ប្រធាន និងតំណាងអង្គការការីតាសស្វីស។
- អមដំណើរលោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ដើម្បីចូលរួមគោរពវិញ្ញាណក្ខន្ធ ឯកឧត្តមទេសរដ្ឋមន្ត្រី ត្រាំ អ៊ីវតឹក រដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ដែលបានធ្វើកាលកិរិយា។
- កិច្ចប្រជុំពិភាក្សាបន្តសម្រាប់ត្រៀមកិច្ចប្រជុំពិគ្រោះ ស្តីពី « គោលការណ៍មិនដាក់ទណ្ឌកម្មលើជនរងគ្រោះដោយអំពើជួញដូរ » ក្រោមអធិបតីភាព លោកជំទាវ **ជូ ប៊ុនអេង** ជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ តាមប្រព័ន្ធអនឡាញ Zoom Video ដែលមានសមាសភាពចូលរួមមាន, ១/ឯកឧត្តម **ហ៊ូ វុឌ្ឍី** រដ្ឋលេខាធិការក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងសហការី, ២/ ឯកឧត្តម **ប៉ែន ពេជ្រសាលី** អគ្គនាយនៃអគ្គនាយកដ្ឋានកិច្ចការអយ្យការនិងព្រហ្មទណ្ឌ៣/លោកឧត្តមសេនីយ៍ឯក **ជីវ ផល្លី** ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្សនៃអគ្គស្នងការដ្ឋាននគរបាលជាតិ, ៤/ឯកឧត្តម ឧត្តមសេនីយ៍ឯក **អ៊ុក ហៃសីឡា** អគ្គនាយករង នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ,៥/លោក **ផុន ពុធបូរី** ប្រធាន នាយកដ្ឋានក្រសួងកិច្ចការនារី,តំណាងក្រសួងសង្គមកិច្ចក្រសួងការបរទេស និងសហប្រតិបត្តិការអន្តជាតិ និងឯកឧត្តមអគ្គលេខាធិការរង ប្រធានក្រុមកិច្ចការយុត្តិធម៌ ប្រធានក្រុមកិច្ចការទេសន្តរប្រវេសន៍ និងប្រធានលេខាធិការ និងក្រុមការងារបច្ចេកទេសនៃគ.ជ.ប.ជនៅសាលប្រជុំ គ.ជ.ប.ជ។
- កិច្ចពិភាក្សា អំពីកិច្ចសហការ ការងារជាមួយ គ.ជ.ប.ជ ពាក់ព័ន្ធលើកិច្ចការទេសន្តរប្រវេសន៍ និងគម្រោងត្រៀមកិច្ចប្រជុំបន្ត ស្តីពីកតិកាសញ្ញាសាកលពិភពលោកស្តីពីទេសន្តរប្រវេសន៍ដោយសុវត្ថិភាព និងរៀបរយ (GCM) ជាពិសេសគម្រោងផែនការអនុវត្តបន្តការងារមួយចំនួនទៀតក្រោមអធិបតីភាពលោកជំទាវ ជូ ប៊ុនអេង ជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ជាមួយនិង លោកស្រីគ្រីស្ទីន ផាកូ ប្រធានអង្គការ(អាយអូអឹម) IOM ប្រចាំប្រទេសកម្ពុជា រួមនិងសហការី និងមានការអញ្ជើញចូលរួមពីឯកឧត្តមអគ្គលេខាធិការរង ការិយាល័យផែនការហិរញ្ញវត្ថុ និងភស្តុភារ នៃគ.ជ.ប.ជ នៅសាលប្រជុំ នៃអគ្គលេខាធិការ គ.ជ.ប.ជ។
- ដឹកនាំកិច្ចសម្ភាសន៍រវាងតំណាងអង្គការ Asean Actនិងអគ្គលេខាធិការដ្ឋាន នៃគណៈកម្មធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សតាមប្រពន្ធ័ អនឡាញ ស្តីពីវឌ្ឍនភាពនៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ចាប់តាំងពីការបង្កើតឡើងរហូតដល់បច្ចុប្បន្ន និងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សក្នុង

ដំណាក់កាលការផ្ទុះរាលដាល ជំងឺកូវីដ១៩ និងការប្រឈមផ្សេងៗទៀតជាចំបង ការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ក្នុងការប្តេជ្ញាចិត្ត ក្នុងការប្រយុទ្ធប្រឆាំង និងអំពើរជួញដូរមនុស្សដែលមានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សជាសេនាធិការរបស់រាជរដ្ឋាភិបាល។ អញ្ជើញចូលរួមមានវត្តមាននាពេលនោះ មានឯកឧត្តមអគ្គលេខាធិការរង ឯកឧត្តមទីប្រឹក្សា ប្រធានក្រុមជំនួយកិច្ចការការពារជនរងគ្រោះ នៅសាលប្រជុំ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ។

- កិច្ចប្រជុំពិភាក្សាស្តីពី «ផលប៉ះពាល់ នៃជំងឺកូវិដ-១៩ លើសិទ្ធិមនុស្សរបស់ជនទេសន្តរប្រវេសន៍» ក្រោមអធិបតីភាពលោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ។ដោយមានការអញ្ជើញចូលរួមពីឯកឧត្តមលោកជំទាវអគ្គលេខាធិការរង ឯកឧត្តមទីប្រឹក្សា លោកប្រធាន/អនុប្រធានលេខាធិការដ្ឋាន ក្រុមការងារទាំង៦ និងមន្ត្រីពាក់ព័ន្ធមួយចំនួនទៀតនៅសាលប្រជុំ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។
- កិច្ចប្រជុំជាមួយអង្គការដៃគូអភិវឌ្ឍន៍ជាតិ អន្តរជាតិ តាមប្រពន្ធអនឡាញ(ZOOM) ស្តីពីការចែករំលែកព័ត៌មានបទពិសោធន៍និងធ្វើបច្ចុប្បន្នភាពការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆមាសទី១ និងទិសដៅឆមាសទី២ ឆ្នាំ២០២១ក្រោមអធិបតីភាព លោកជំទាវ **ជូ ប៊ុនអេង** ជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ដោយមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ អគ្គលេខាធិការរង លោកទីប្រឹក្សាបច្ចេកទេស ប្រធាន អនុប្រធានលេខាធិការដ្ឋាន ប្រធានក្រុមការងារទាំង៦ និងមានការចូលរួមពីតំណាងអង្គការដៃគូពាក់ព័ន្ធជាតិ អន្តរជាតិតាមប្រពន្ធអនឡាញមួយចំនួន រួមទាំងមន្ត្រីពាក់ព័ន្ធ នៃអគ្គលេធិការដ្ឋាន គ.ជ.ប.ជ សរុបចំនួន ៤៧ រូប នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។
- កិច្ចជំនួបរវាងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ជាមួយនឹងតំណាងស្ថានទូតសហរដ្ឋអាម៉េរិក និងទីប្រឹក្សារបស់ស្ថានទូត ជួបពិភាក្សាស្តីអំពីវឌ្ឍនភាពកិច្ចការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រោមអធិបតីភាពលោកជំទាវ **ជូ ប៊ុនអេង** ជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ។ ដោយមានការអញ្ជើញចូលរួមពីលោក **អៀង ប៊ុនថន** ទីប្រឹក្សា ឯកឧត្តម **យ៉ែម ច័ន្ទណារុំ** អគ្គលេខាធិការរង លោក **អ៊ុំ គាមិន្ទ** អនុប្រធានលេខាធិការដ្ឋាន នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ នៅសាលប្រជុំ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ។
- ពិធីចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នា រវាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអង្គការវីវើលអនឡូស ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់លោកជំទាវ **ជូ ប៊ុនអេង** ជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ និងខាងភាគីអង្គការវីវើលអនលូស ដឹកនាំដោយ លោកស្រី Simona Capocasale ( Country Representation) ។ ដោយមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ អគ្គលេខាធិការរង ឯកឧត្តម ទីប្រឹក្សា និងលោក លោកស្រី ជាសហការី និងមន្ត្រីពាក់ព័ន្ធមួយចំនួនទៀត សាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ។
- កិច្ចប្រជុំពិគ្រោះយោបល់តុមូលតាមប្រព័ន្ធវីដេអូអនឡាញOnline «ស្តីពីគោលការណ៍មិនដាក់ទណ្ឌកម្មលើជនរងគ្រោះដោយអំពើជួញដូរ» ក្រោមអធិបតីភាពលោកជំទាវ ជូ ប៊ុនអេង ជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ដោយមានការអញ្ជើញចូលរួមពីឯកឧត្តម ហ៊ូ វុឌ្ឍី រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងឯកឧត្តម លោកជំទាវ ជាអគ្គលេខាធិការរង ប្រធានលេខាធិការដ្ឋាន នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ឯកឧត្តម អគ្គនាយកនៃនាយកដ្ឋានអយ្យការ និងកិច្ចការព្រហ្មទណ្ឌ ប្រធាននាយកដ្ឋាន ប្រឆាំងការជួញដូរមនុស្ស ការពារអនីតិជន អគ្គនាយករង នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ តំណាងក្រសួងសង្គមកិច្ចជាប្រធាន នាយកដ្ឋានប្រឆាំងការជួញដូរ សមាហរនកម្មជនរងគ្រោះ តំណាងក្រសួងកិច្ចការនារី ជាប្រធាននាយកដ្ឋាន ប្រធាននាយកដ្ឋាននីតិកម្ម នៃក្រសួង

អប់រំយុវជន និងកីឡា  អ្នកសម្របសម្រួលគម្រោង AATIP គម្រោងអាស៊ាន អូស្រ្តាលីជាតំណាងចូលរួម និងតំណាងពីអង្គការដៃគូរពាក់ព័ន្ធ នៅសាលប្រជុំនៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ។

- កិច្ចប្រជុំ  ស្តីពីផែនការសកម្មភាពការងារជាអាទិភាពត្រូវអនុវត្ត  និងអំពីរបៀបរបបការងារប្រចាំថ្ងៃរបស់អគ្គលេខាធិការដ្ឋាន  គ.ជ.ប.ជ  ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់លោកជំទាវ **ជូ ប៊ុនអេង** ជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ។ ក្នុងកិច្ចប្រជុំនេះមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ អគ្គលេខាធិការរង និងប្រធានក្រុមជំនួយកិច្ចការទាំង៦ នៃអគ្គលេខាធិការដ្ឋាន គ .ជ.ប.ជ នៅសាលប្រជុំនៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ។
- ការប្រគល់  ទទួលសៀវភៅ  របាយការណ៍លទ្ធផលសកម្មភាពការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០២០  និងទិសដៅ  អនុវត្តឆ្នាំ២០២១  របស់គ.ជ.ប.ជ ក្រោមអធិបតីភាពលោកជំទាវ **ជូ ប៊ុនអេង** ជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ  និងតំណាងអង្គការអាស៊ាន-អាក់ Asian-Act ដែលជាអ្នក ឧបត្ថម្ភគាំទ្រដល់ការបោះពុម្ពផ្សាយរបាយការណ៍នេះ និងមានការអញ្ជើញចូលរួមពី ឯកឧត្តមលោកជំទាវ អគ្គលេខាធិការរង ប្រធានលេខាធិការដ្ឋាន និងមន្រ្តីក្រោមឱវាទរបស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ នៅសាលប្រជុំ អគ្គលេខាធិការ គ.ជ.ប.ជ ។
- ជាអធីបភាព ក្នុងកិច្ចប្រជុំក្រុមការងារបច្ចេកទេស គណៈកម្មការការពារកុមារថ្នាក់ជាតិ ដើម្បីពិនិត្យ និងផ្តល់យោបល់ « លើសេចក្តីព្រាងផែនការសម្មភាពសម្រាប់អនុវត្តគោលនយោបាយជាតិ ស្តីពីប្រព័ន្ធកិច្ចការពារកុមារឆ្នាំ  ២០១៩-២០២៩ »  ដោយអញ្ជើញចូលរួមជាមួយ លោកជំទាវ  **ញ៉េប សុភាព** អគ្គលេខាធិការ  នៃអគ្គលេខាធិការដ្ឋាន  ក.ជ.ក  រៀបចំដោយអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារដោយទទួលបានកិច្ចសហការឧបត្ថមដោយអង្គការPlan  International Cambodia នៅសាលប្រជុំ សាលាខេត្តកំពង់ចាម ខេត្តកំពង់ចាម ។
- កិច្ចប្រជុំ ស្តីពីផែនការសកម្មភាពការងារជាអទិភាពត្រូវអនុវត្តឆ្នាំ២០២១ និងឆ្នាំបន្ទាប់របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ក្រោមកិច្ចអធិបតីភាព លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ  និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ។ អញ្ជើញចូលរួមក្នុងកិច្ចប្រជុំនេះមាន ឯកឧត្តម លោកជំទាវ អគ្គលេខាធិការរង ប្រធានលេខាធិការដ្ឋាន រដ្ឋបាល-សរុប  និង ប្រធានក្រុមជំនួយកិច្ចការទាំង ៦ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ នៅសាលប្រជុំ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ។
- កិច្ចប្រជុំ ស្តីពីផែនការសកម្មភាព ការងារជាអទិភាពត្រូវអនុវត្ត នៅឆមាសទី២ ឆ្នាំ២០២១  របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ក្រោមអធិបតីភាពដឹកនាំដោយលោកជំទាវ **ជូ ប៊ុនអេង** ជាអនុប្រធានអចិន្ត្រៃយ៍  គ.ជ.ប.ជ  ដោយមានការអញ្ជើញចូលរួមពី  ឯកឧត្តម លោកជំទាវ អគ្គលេខាធិការរង  ប្រធានក្រុមជំនួយកិច្ចការ នៃក្រុមជំនួយកិច្ចទាំង៦របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។
- កិច្ចប្រជុំ ជាមួយអង្គការ (ASIAN-ACT) តាមរយះវីដេអូអនឡាញស្តីពី៖ កិច្ចសហការណ៍រវាងគ.ជ.ប.ជ និងអង្គការ(ASIAN-ACT)ក្នុងឆមាសទី២ ឆ្នាំ២០២១ ក្រោមអធិបតីភាព លោកជំទាវ ជូ  ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ  និងជាអនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ ។ អញ្ជើញចូលរួមក្នុងកិច្ចប្រជុំនេះមាន ឯកឧត្តម លោកជំទាវ អគ្គលេខាធិការរង ទីប្រឹក្សាអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ នៅសាលប្រជុំ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ។

- អមដំណើរលោកជំទាវ **ជូ ប៊ុនអេង** ជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ អនុប្រធានក្រុមការងារថ្នាក់ជាតិ តាមដានត្រួតពិនិត្យគោលនយោបាយ ភូមិ/ឃុំមានសុវត្ថិភាពខេត្តកំពង់ឆ្នាំង អញ្ជើញចូលរួមគោរពវិញ្ញាណក្ខន្ធ និងប្រគល់ថវិកាចូលរួមបុណ្យ ពីថ្នាក់ដឹកនាំ មន្ត្រីក្រោមឱវាទរបស់ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ជូនដល់ពិធីបុណ្យសព ឧបាសិកា អ៊ុន គឹមសាន ត្រូវជា ម្តាយ បង្កើតឯកឧត្តម **ហ៊ី ណាត** ទីប្រឹក្សាក្រសួងមហាផ្ទៃ ដែលបានទទួលមរណៈ ក្នុងជន្មាយុ ៩១ឆ្នាំ ដោយរោគា ពាធដែលសរបានតំកល់ធ្វើបុណ្យ នៅគេហដ្ឋាន របស់ឯកឧត្តម ឋិតក្នុងភូមិម៉ុងបារាំង សង្កាត់ប្អេរក្រុងកំពង់ឆ្នាំង។
- កិច្ចប្រជុំពិភាក្សា ស្តីអំពីរបៀបរបបការងារ នៃការប្រព្រឹត្តិទៅរបស់មណ្ឌលទទួលពលករ និងការប្រគល់ទទួល សម្ភារៈបច្ចេកទេស ជូនបុគ្គលិក និងមន្ត្រីប្រចាំជូនមណ្ឌលទទួលពលករស្រុកកំរៀង ក្រោមអធិបតីភាពលោកជំទាវ **ជូ ប៊ុនអេង** ជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ និងមានការចូលរួមពីលោកអភិបាលស្រុកកំរៀង លោកជំទាវ អគ្គលេខាធិការរង និងប្រធាន ក្រុមការងារសហប្រតិបត្តិការអន្តរជាតិ នៃ លោកស្រីអភិបាលរងខេត្តបាត់ដំបង ស្នងការរងនគរបាលខេត្ត សហការីរបស់អង្គការការីតាសស្វីស មន្ត្រីតំណាងពីមន្ទីការងារ មន្ទីរសង្គមកិច្ច និងមន្ត្រីសាលាស្រុកកំរៀង។
- កិច្ចប្រជុំ ស្តីពីវឌ្ឍភាពការងារឆមាសទី១ ឆ្នាំ២០២១ ដោយផ្តោតសំខាន់លើ មាតុភូមិនិវត្តន៍ស្តារ និតិសម្បទា,សមាហរណកម្ម តាមរយៈវីដេអូ (ZOOM) ដែលដឹកនាំប្រជុំដោយ នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងសមាហរណកម្ម ជនរងគ្រោះ ស.អ.យ ។ ដោយមានការអញ្ជើញចូលរួមពីឯកឧត្តម ឧត្តមសេនីយ៍ឯក **លី តុងហ៊ុយ** អគ្គលេខាធិការរង នៃក្រុមការងារជួយជនរងគ្រោះ នៃអគ្គលេខាធិការ គ.ជ.ប.ជ និង សមាសភាពចូលរួមមាន ៥៣នាក់ មកពីក្រសួង អង្គភាពពាក់ពន្ធ័ និងអង្គការដៃគូនានា នៅសាលប្រជុំ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។
- **លេខាធិការដ្ឋាន នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បានអនុវត្តធ្វើ៖ ១**-លិខិតរបស់ គ.ជ.ប.ជ៖ លិខិតចេញ (១០ច្បាប់) លិខិតចូល (០៣ច្បាប់)។ **២**-លិខិតរបស់ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖ លិខិតចេញ (១៨ច្បាប់) លិខិតចូល (១៣ច្បាប់)។ **៣**-ស្រង់វត្តមានប្រចាំថ្ងៃ ដើម្បីតាមដានការងារប្រចាំថ្ងៃរបស់មន្ត្រី។ **៤**-រៀបចំកិច្ចប្រជុំ និងធ្វើកំណត់ហេតុ រៀងរាល់កិច្ចប្រជុំ។ **៥**-បូកសរុបរបាយការណ៍ប្រចាំសប្តាហ៍និងខែឧសភា ឆ្នាំ២០២១ របស់អគ្គលេខាធិការដ្ឋានគ.ជ.ប.ជ។ **៦**-ប្រមូលរបាយការណ៍ពីអន្តរក្រសួង ស្ថាប័ន និងរាជធានី/ខេត្តទាំង២៥។ **៧**-រៀបចំ និងបញ្ជូនលិខិតអញ្ជើញចូលរួមប្រជុំ ទៅកាន់ក្រសួង ស្ថាប័ន អង្គភាព រាជធានី-ខេត្ត និងអង្គការដៃគូពាក់ព័ន្ធនានា។ ៨-ចងក្រងព័ត៌មាន រូបភាព និងសកម្មភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិចូលក្នុងបណ្ណាគារវីគី។ **៩**-គ្រប់គ្រងទំព័រហ្វេសប៊ុក របស់លោកជំទាវអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។ **១០**-គ្រប់គ្រងទំព័រហ្វេសប៊ុក របស់លោកជំទាវអគ្គលេខាធិការ គ.ជ.ប.ជ។ **១១**-ព័ត៌មានស្រាវជ្រាវ ពីគេហទំព័រព័ត៌មាននានា រក្សាទុកក្នុងបណ្ណាល័យ wiki ncct convert ជា PDF បានចំនួន១៥៥ច្បាប់និងបានចងក្រងជាសៀវភៅដាក់ជូនលោកជំទាវរដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ និងជូនលោកជំទាវឧត្តមសេនីយ៍ឯក អគ្គលេខាធិការ នៃ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។ **១២**-អាប់ឡូតរូបភាពសកម្មភាព គ.ជ.ប.ជ និង គ.ខ.ប.ជ ចូលបណ្ណាល័យរូបភាពក្នុងប្រព័ន្ធ Wiki បានចំនួន ២០សកម្មភាព។ **១៣**-អាប់ឡូតឯកសារចូលបណ្ណាល័យវីគីបានចំនួន ៦២ច្បាប់។ **១៤**-បង្កើតផេកថ្មីក្នុងបណ្ណាល័យវីគីសម្រាប់រក្សាទុកឯកសារ និងរូបភាពសកម្មភាពរបស់ លោកជំទាវ។ ១៥- ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។ **១៦**-លិខិតស្នើសុំបង់ថ្លៃអ៊ិនធើណេតសម្រាប់ខែ មិថុនា ឆ្នាំ២០២១។ **១៧**-ធ្វើបច្ចុប្បន្នភាពការងារព័ត៌មាន ទៅក្នុងគេហទំព័រ និងតាមបណ្តាញទំនាក់ ទំនងសង្គមផ្លូវការរបស់ គ.ជ.ប.ជ ស្តីអំពីសកម្មភាពការងារថ្នាក់ដឹកនាំ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។ **១៨**-ការសហការ ស្រាវជ្រាវ ប្រមែប្រមូល ព័ត៌មានពីគ្រប់មជ្ឈដ្ឋាន ដើម្បីធ្វើការពិនិត្យ

វិភាគ សន្និដ្ឋាន វាយតម្លៃរាល់សកម្មភាព ដែលទាក់ទង នឹងអំពើជួញដូរមនុស្ស។ ១៩-សហការជាមួយក្រុមការងារ ចម្រុះទទួលពលករ (ប៉ោយប៉ែត) ក្នុងការប្រមូលព័ត៌មាន និងទិន្នន័យពលករ បញ្ជូនត្រឡប់ពីប្រទេសថៃ តាមប្រព័ន្ធបញ្ចូល ទិន្នន័យស្វ័យប្រវត្តិ។ ២០-ថែទាំប្រព័ន្ធអ៊ិនធើណែត និងម៉ាស៊ីន Sever និងអនុវត្តការងារជាក់ស្តែងមួយចំនួន ដែលថ្នាក់ដឹកនាំដាក់បញ្ជាមក។ ២១-ចូលរួមពិភាក្សាការងារ ស្តីពីរបៀបរបបការងារ នៃការប្រព្រឹត្តិទៅមណ្ឌលទទួលពលករប្រចាំមណ្ឌលទទួលពលករស្រុកកំរៀង ខេត្តបាត់ដំបងជាមួយថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។ ២២-ធ្វើ Backdrop ពិធីចុះអនុស្សរណៈយោគយល់គ្នា រវាងគ.ជ.ប.ជ និងអង្គការវីវើលអនលូស(We World Onlus)។

▪ **ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់** ឯកឧត្តម ឧត្តមសេនីយ៍ទោ កែវ សុវណ្ណារ៉ា អគ្គលេខាធិការរងបានអញ្ជើញ និងដឹកនាំ៖

- លោកប្រធានក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ចូលរួមកិច្ចប្រជុំពិភាក្សា ស្តីពី ផលប៉ះពាល់ នៃជំងឺកូវីដ-១៩ លើសិទ្ធិមនុស្សរបស់ជនទេសន្តរប្រវេសន៍ ក្រោមអធិបតីភាព លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ ដោយមានការអញ្ជើញចូលរួមពីលោកជំទាវ អគ្គលេខាធិការ ឯកឧត្តម លោកជំទាវ អគ្គលេខាធិការរង ឯកឧត្តមទីប្រឹក្សា លោកប្រធាន/អនុប្រធានលេខាធិការដ្ឋាន ក្រុមការងារទាំង៦ និងមន្ត្រីពាក់ព័ន្ធ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ មួយចំនួនទៀត។
- លោកប្រធានក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់បានអញ្ជើញចូលរួមកិច្ចប្រជុំពិភាក្សា ស្តីពីផលប៉ះពាល់ នៃជំងឺកូវីដ-១៩ លើសិទ្ធិមនុស្សរបស់ជនទេសន្តរប្រវេសន៍ ក្រោមអធិបតីភាព លោកជំទាវឧត្តមសេនីយ៍ឯក ប៊ុណ្ណ សំខាន់ អគ្គលេខាធិការ និងមានការអញ្ជើញចូលរួមពីឯកឧត្តម លោកជំទាវ អគ្គលេខាធិការរង ទីប្រឹក្សា លោកប្រធាន/អនុប្រធានលេខាធិការដ្ឋាន ក្រុមការងារទាំង៦ និងមន្ត្រីពាក់ព័ន្ធនៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ មួយចំនួនទៀត។
- លោកឧត្តមសេនីយ៍ទោ វ៉ែនសុភ័ក្រ្តវឌ្ឍនា ប្រធានក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ បានអញ្ជើញចូលរួមកិច្ចប្រជុំ ស្តីពីផែនការសកម្មភាពការងារជាអទិភាពត្រូវអនុវត្ត និង អំពីរបៀបរបបការងារប្រចាំថ្ងៃរបស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ក្រោមអធិបតីភាព លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ .ជ.ប.ជ និងមានការអញ្ជើញចូលរួមពី លោកជំទាវឧត្តមសេនីយ៍ឯក ប៊ុណ្ណ សំខាន់ អគ្គលេខាធិការ គ.ជ.ប.ជ ឯកឧត្តម លោកជំទាវ អគ្គលេខាធិការរង និង ប្រធានក្រុមជំនួយកិច្ចការទាំង៦ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។
- លោកឧត្តមសេនីយ៍ទោ ប្រធានក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ ចូលរួមកិច្ចប្រជុំ ស្តីពីផែនការសកម្មភាពការងារជាអទិភាពត្រូវអនុវត្តឆ្នាំ២០២១ និងឆ្នាំបន្ទាប់ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ក្រោមអធិបតីភាព លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ និងមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ អគ្គលេខាធិការរង និងប្រធានក្រុមជំនួយកិច្ចការ ៦ របស់អគ្គលេខាធិការដ្ឋាន គ .ជ.ប.ជ។
- ចូលរួមក្នុងពិធីចុះហត្ថលេខាលើអនុស្សរណយោគយល់គ្នា រវាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអង្គការវីវើលអនឡុស។ខាងភាគី គណៈកម្មាធិការជាតិគ.ជ.ប.ជ ដឹកនាំដោយលោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ខាងភាគីអង្គការវីវើលអនលូស ដឹកនាំដោយ លោកស្រី Simona Capocasale ( Country Representation) ដោយមានការអញ្ជើញចូលរួមពី លោកជំទាវអគ្គលេខាធិការ គ.ជ.ប.ជ ឯកឧត្តម លោកជំទាវ អគ្គលេខាធិការរង ឯកឧត្តម ទីប្រឹក្សា និងលោក លោកស្រី ជាសហការី និងមន្ត្រីពាក់ព័ន្ធមួយចំនួនទៀត។

- លោកអនុ.ឯក ហង្ស ពុទ្ធារិទ្ធិ បានចូលរួមធ្វើជាគ្រូឧទ្ទេសជាមួយក្រុមគ្រូឧទ្ទេសថ្នាក់ជាតិក្រសួងអប់រំ យុវជន និងកីឡាដែលដឹកនាំដោយលោកជំទាវ **សឿ សុជាតា** អនុរដ្ឋលេខាធិកាក្នុងវគ្គសិក្ខាសាលាបណ្តុះបណ្តាល សៀវភៅអប់រំស្តីពីការបង្ការ ទប់ស្កាត់ និងលំនាំនៃការបង្រៀន ជូនលោកគ្រូអ្នកគ្រូនៅខេត្តកំពង់ឆ្នាំង តាមប្រព័ន្ធហ្សូម (zoom) ដែលប្រព្រឹត្តទៅរយៈពេល០៤ថ្ងៃ ចាប់ពីថ្ងៃទី២៧ ដល់ថ្ងៃទី៣០ខែមិថុនា ២០២១។
- បូកសរុបលទ្ធផលសកម្មភាពការងារប្រចាំខែ របស់ក្រុមការងារបង្ការ ទប់ស្កាត់ ដោយធ្វើការបូកសរុបលទ្ធផលពីបណ្តារាជធានី-ខេត្ត និងក្រសួង-ស្ថាប័នពាក់ព័ន្ធ។
- តាមដានព័ត៌មានជាប្រចាំតាមរយៈបណ្តាញសង្គមនានា និងតាមរយៈ Telegram របស់ក្រុមការងារថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ពាក់ព័ន្ធនឹងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងការងារផ្សព្វផ្សាយស្តីពីការបង្ការ ទប់ស្កាត់ ភាពរងគ្រោះដល់ប្រជាពលរដ្ឋនៅតាមសហគមន៍។

▪ **ក្រុមជំនួយកិច្ចការយុត្តិធម៌** ឯកឧត្តម ឧត្តមសេនីយ៍ទោ **នី គឹមស្រេន** អគ្គលេខាធិការរង និងលោកប្រធានក្រុមការងារ បានអញ្ជើញចូលរួមកិច្ចប្រជុំពិភាក្សា៖

- ស្តីពី «គោលការណ៍មិនដាក់ទណ្ឌកម្មលើជនរងគ្រោះដោយអំពើជួញដូរ» តាមប្រព័ន្ធ Zoom Video ជាមួយថ្នាក់ដឹកនាំអគ្គលេខាធិការរង ប្រធានក្រុមជំនួយកិច្ចការទេសន្តរប្រវេសន៍និងប្រធានលេខាធិការដ្ឋាន និងតំណាងអន្តរក្រសួង ស្ថាប័ននៃក្រុមការងារជំនាញទាំង០៦ ស្តីពីប្រធានបទសំខាន់ចំនួន០៣ គឺ៖១.ការបកស្រាយ និងការអនុវត្តច្បាប់រដ្ឋបាល និងច្បាប់ព្រហ្មទណ្ឌដើម្បីការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស ២.ការអនុវត្តគោលនយោបាយ គោលការណ៍ណែនាំ និងកិច្ចព្រមព្រៀងក្នុងតំបន់ដែលទាក់ទងនឹងការមិនដាក់ទណ្ឌកម្ម និង ៣. បញ្ហាប្រឈម ការប្រតិបត្តិល្អ និងមេរៀនដែលបានទទួល ក្នុងការលើកស្ទួយ និងការអនុវត្តគោលការណ៍មិនដាក់ទណ្ឌកម្មក្រោមការដឹកនាំសម្របសម្រួលដោយ **លោកជំទាវ រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ** និងជា **អនុ ប្រធានអចិន្ត្រៃយ៍** និង **លោកជំទាវ ឧត្តមសេនីយ៍ឯក អគ្គលេខាធិការ** គ.ជ.ប.ជ ។
- ជាមួយឯកឧត្តមទីប្រឹក្សា លោកប្រធាន/អនុប្រធានលេខាធិការដ្ឋាន ប្រធានក្រុមជំនួយកិច្ចការការពារជនរងគ្រោះ អនុវត្តច្បាប់ បង្ការទប់ស្កាត់ និងមន្ត្រីពាក់ព័ន្ធមួយចំនួនទៀត នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជស្តីពី <ផលប៉ះពាល់ នៃជំងឺកូវីដ-១៩ លើសិទ្ធិមនុស្សរបស់ជនទេសន្តរប្រវេសន៍> តាមសំណើសុំផ្តល់ធាតុចូលរបស់អ្នករាយការណ៍ពិសេសស្តីពី សិទ្ធិមនុស្សរបស់ជនទេសន្តរប្រវេសន៍នៃការិយាល័យឧត្តមស្នងការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស(OHCHR) ឱ្យបានមុនថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២១ រួមមានចំនួន០៨ សំនួរ ដែលកិច្ចប្រជុំត្រូវពិភាក្សារកធាតុចូលចំនួន ៥ ទំព័រ ក្រោមអធិបតីភាពលោក**ជំទាវ រដ្ឋលេខាធិការក្រសួងមហាផ្ទៃ** និងជាអនុ**ប្រធានអចិន្ត្រៃយ៍** និង**លោកជំទាវ ឧត្តមសេនីយឯក អគ្គលេខាធិការ** គ.ជ.ប.ជ ។
- រួមជាមួយ ឯកឧត្តម អគ្គលេខាធិការរងចំនួន០២នាក់ គឺ **លី តុងហ៊ុយ** និង **តែ សុថារ៉េត** នៅក្នុងសិក្ខាសាលាពិគ្រោះយោបល់ ស្តីពី(តុលាការដែលយកចិត្តទុកដាក់លើជនរងគ្រោះដោយអំពើជួញដូរមនុស្ស) តាមប្រព័ន្ធ Zoom រៀបចំឡើងដោយអង្គការ ASEAN-ACT និងគាំទ្រដោយក្រសួងយុត្តិធម៌ ក្រោមអធិបតីភាពឯកឧត្តម **ប៉ែន ពេជ្រសាលី** អគ្គនាយកកិច្ចការអយ្យការ និងព្រហ្មទណ្ឌ នៃក្រសួងយុត្តិធម៌ និងជាប្រធានក្រុមការងារបច្ចេកទេស នៃកម្មវិធីអាស៊ាន-អូស្ត្រាលីប្រឆាំងការជួញដូរមនុស្ស (ASEAN-ACT) ដោយមានសមាសភាពចូលរួមពីភាគីពាក់ព័ន្ធក្នុង និងក្រៅប្រទេសចំនួន ៧៤ រូប(ស្រី៣០រូប)។
- បន្តជាមួយឯកឧត្តមទីប្រឹក្សា លោកប្រធាន/អនុប្រធានលេខាធិការដ្ឋាន ប្រធានក្រុមជំនួយកិច្ចការការពារជនរងគ្រោះ អនុវត្តច្បាប់ បង្ការទប់ស្កាត់ និងមន្ត្រីពាក់ព័ន្ធមួយចំនួនទៀត នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជស្តីពី <ផលប៉ះពាល់ នៃជំងឺកូវីដ-១៩ លើសិទ្ធិមនុស្សរបស់ជនទេសន្តរប្រវេសន៍> ក្រោមការដឹកនាំសម្របសម្រួលដោយ **លោកជំទាវ ឧត្តមសេនីយឯក អគ្គលេខាធិការ** គ.ជ.ប.ជ ។
- ជាមួយថ្នាក់ដឹកនាំអគ្គលេខា ធិការដ្ឋាន និងអង្គការដៃគូអភិវឌ្ឍន៍ជាតិ អន្តរជាតិ តាមប្រពន្ធអនឡាញ(ZOOM) សរុបចំនួន ៤៧ រូប ស្តីពីការ ចែករំលែកព័ត៌មានបទពិសោធន៍ និងធ្វើបច្ចុប្បន្នភាពការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆមាសទី១ និង ទិសដៅឆមាសទី២ ឆ្នាំ២០២១ ក្នុងគោលបំណងឱ្យអង្គការដៃគូបាន

ជ្រាប និងចែករំលែកព័ត៌មានគ្រឡប់ អំពីលទ្ធផលការងារ និងគម្រោងការនានាដែលអាចបន្សីគ្នា ឬផ្សាភ្ជាប់គ្នាជាមួយថ្នាក់ជាតិ ក៏ដូចជាដំណោះស្រាយសម្រាប់ភាពប្រឈមនានា ដើម្បីបង្កើនប្រសិទ្ធិភាពការងារប្រឆាំងការជួញដូរមនុស្ស ក្រោមអធិបតីភាព **លោកជំទាវរដ្ឋលេខាធិការក្រសួងមហាផ្ទៃ** និងជា**អនុប្រធានអចិន្ត្រៃយ៍** និង **លោកជំទាវ ឧត្តមសេនីយ៍ឯក អគ្គលេខាធិការ គ.ជ.ប.ជ** ។

- ពិគ្រោះយោបល់តុមូល តាមប្រព័ន្ធវីដេអូអនឡាញ «ស្តីពីគោលការណ៍មិនដាក់ទណ្ឌកម្មលើជនរងគ្រោះដោយអំពើជួញដូរ» ជាមួយថ្នាក់អគ្គលេខាធិការរង និងតំណាងក្រុមការងារ ជំនាញអន្តរក្រសួងស្ថាប័នពាក់ព័ន្ធទាំង០៦ អ្នកសម្របសម្រួលគម្រោង AATIP គម្រោងអាស៊ាន អូស្ត្រាលី (ASEAN-ACT) និងតំណាងពីអង្គការដៃគូពាក់ព័ន្ធជាច្រើនដោយមានការចោទសួរអំពី ប្រធានបទនានាទៅកាន់តំណាងស្ថាប័នចូលរួម មន្ត្រីជំនាញ និងអ្នកអនុវត្តផ្ទាល់ ក្រោមអធិបតីភាព **លោកជំទាវ រដ្ឋលេខាធិការក្រសួងមហាផ្ទៃ** និងជា**អនុប្រធានអចិន្ត្រៃយ៍** និង **លោកជំទាវ ឧត្តមសេនីយឯក អគ្គលេខាធិការ គ.ជ.ប.ជ** ។
- ជាមួយអគ្គលេខាធិការរងទាំងអស់ ប្រធានក្រុមជំនួយកិច្ចការ ទេសន្តរប្រវេសន៍ និងប្រធានក្រុមជំនួយកិច្ចការបង្ការទប់ស្កាត់ ស្តីពីផែនការសកម្មភាពការងារជាអទិភាពដែលត្រូវអនុវត្តក្នុងនាមជាអ្នកប្រមូលព័ត៌មានពាក់ព័ន្ធជំនាញផង និងជាអ្នកអនុវត្តអនុសកម្មភាពផង ដើម្បីរំលឹកឡើងវិញថា តើក្រោយពីបានធ្វើផែនការតាមក្រុមជំនួយកិច្ចការនីមួយៗរួចហើយ ០៦ខែទៅមុខទៀតយើងត្រូវធ្វើអ្វីខ្លះ និងអំពីរបៀបរបបការងារប្រចាំថ្ងៃរបស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ក្រោមអធិបតីភាព **លោកជំទាវរដ្ឋលេខាធិការក្រសួងមហាផ្ទៃ** និងជា**អនុប្រធានអចិន្ត្រៃយ៍** និង**លោកជំទាវ ឧត្តមសេនីយ៍ឯក អគ្គលេខាធិការគ.ជ.ប.ជ**។
- ជាមួយឯកឧត្តមលោកជំទាវ អគ្គលេខាធិការរង ប្រធានលេខាធិការដ្ឋាន និងមន្ត្រីក្រោមឱវាទរបស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ នៅក្នុងពិធីប្រគល់-ទទួលសៀវភៅរបាយការណ៍លទ្ធផលសកម្មភាពការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០២០ និងទិសដៅអនុវត្តឆ្នាំ២០២១ របស់គ.ជ.ប.ជ ពីតំណាងអង្គការ Asian-Act ដែលជាអ្នកឧបត្ថម្ភគាំទ្រដល់ការបោះពុម្ពផ្សាយសៀវភៅរបាយការណ៍នេះ ក្រោមអធិបតីភាព**លោកជំទាវ រដ្ឋលេខាធិការក្រសួងមហាផ្ទៃ** និងជា**អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ** និងតំណាងអង្គការអាស៊ាន-អាក់ (Asian-Act) ។
- ជាមួយឯកឧត្តមលោកជំទាវអគ្គលេខាធិការរង ប្រធានលេខាធិការដ្ឋាន និងប្រធានក្រុមជំនួយកិច្ចការចំនួន០៣(គឺ ទេសន្តប្រវេសន៍ បង្ការទប់ស្កាត់ និងកិច្ចការអនុវត្តច្បាប់) ដើម្បីប្រជុំបន្ត ស្តីពីផែនការសកម្មភាពការងារជាអទិភាពដែលត្រូវអនុវត្តឆ្នាំ២០២១ និងឆ្នាំបន្ទាប់របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ក្រោមអធិបតីភាព **លោកជំទាវរដ្ឋលេខាធិការក្រសួងមហាផ្ទៃ** និងជា**អនុប្រធានអចិន្ត្រៃយ៍** គ.ជ.ប.ជ ។ និងប្រជុំនៅថ្ងៃបានចូលរួមជាមួយឯកឧត្តម/លោកជំទាវអគ្គលេខាធិការរងចំនួន០៣រូប (រ៉ន សិរីលក្ខិណា នីគីមស្រេន និង តែ សុថារ៉េត) ប្រធានក្រុមជំនួយកិច្ចការអនុវត្តច្បាប់ និងលោកវ.ឯក អោក សត្យា នៅក្នុងកិច្ចប្រជុំស្តីពីផែនការសកម្មភាពការងារជាអទិភាពត្រូវអនុវត្តឆ្នាំ២០២១ និងឆ្នាំបន្ទាប់ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ក្រោមអធិបតីភាព **លោកជំទាវ រដ្ឋលេខាធិការក្រសួងមហាផ្ទៃ** និងជា**អនុប្រធានអចិន្ត្រៃយ៍** និង **លោកជំទាវ ឧត្តមសេនីយ៍ឯក អគ្គលេខាធិការ គ.ជ.ប.ជ** ។

▪ **ក្រុមជំនួយកិច្ចការការពារជនរងគ្រោះ**: ឯកឧត្តម អគ្គលេខាធិការរង **លី តុងហ៊ុយ** ទទួលបន្ទុកក្រុមការងារការពារជនរងគ្រោះ បានអញ្ជើញចូលរួម៖

- សិក្ខាសាលាពិគ្រោះយោបល់ ស្តីពីកិច្ចការតុលាការក្នុងការយកចិត្តទុកដាក់លើជនរងគ្រោះដោយអំពើជួញដូរមនុស្ស តាមប្រព័ន្ធអនឡាញ Zoom ក្រោមអធិបតីភាព ឯកឧត្តម **ប៉ែន ពេជ្រសាលី** អគ្គនាយក កិច្ចការអយ្យការ និងព្រហ្មទណ្ឌ នៃក្រសួងយុត្តិធម៌ និងជាប្រធានការងារបច្ចេកទេស នៃកម្មវិធីអាស៊ាន អូស្ត្រាលីប្រឆាំងការជួញដូរមនុស្ស ASEAN-ACTS សមាសភាពចូលរួម តាមប្រព័ន្ធអនឡាញ Zoom រួមមានចំនួន ១០រូប៕
- និងដឹកនាំលោកប្រធានក្រុមការងារបានចូលរួមកិច្ចប្រជុំពិភាក្សាជាមួយអង្គការ ដៃគូអភិវឌ្ឍន៍ជាតិ និងអន្តរជាតិ ស្តីពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរយៈពេល៦ខែដើមឆ្នាំ២០២១ និងគម្រោងសកម្មភាព ជាទិសដៅបន្តសម្រាប់ឆមាសទី២ ឆ្នាំ២០២១ ក្រោមអធិបតីភាពលោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការ ក្រសួង

មហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។កិច្ចប្រជុំនេះមានការអញ្ជើញចូលរួមពីលោកជំទាវ អគ្គលេខាធិការ ឯកឧត្តម លោកជំទាវ អគ្គលេខាធិការរង ប្រធានក្រុមជំនួយការទាំង៦ ប្រធានលេខាធិការដ្ឋានរដ្ឋបាលសរុប និងអ្នកពាក់ព័ន្ធមួយចំនួនទៀតនៅសាលប្រជុំ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ។

- ប្រជុំពិភាក្សារវាងថ្នាក់ដឹកនាំអគ្គលេខាធិការ គ.ជ.ប.ជ តំណាងស្ថានទូតអាម៉េរិក និងទីប្រឹក្សារបស់ស្ថានទូតស្តីពីៈវឌ្ឍនភាព ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រោមអធិបតីភាពលោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។ ដោយមានអញ្ជើញចូលរួមពី លោកជំទាវ អគ្គលេខាធិការ ឯកឧត្តម លោកជំទាវ អគ្គលេខាធិការរង ប្រធានលេខាធិការដ្ឋាន រដ្ឋបាល សរុប គ.ជ.ប.ជ និងមន្ត្រីពាក់ព័ន្ធមួយចំនួនទៀតនៅសាលប្រជុំ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ។
- កិច្ចប្រជុំពិគ្រោះយោបល់តុមូលតាមប្រព័ន្ធវីដេអូអនឡាញ ស្តីពីគោលការណ៍មិនដាក់ទណ្ឌកម្មលើជនរងគ្រោះដោយអំពើជួញដូរ )ក្រោមអធិបតីភាព លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ និងដោយមានការអញ្ជើញចូលរួមពី ឯកឧត្តម **ហ៊ី វុឌ្ឍី** រដ្ឋលេខាធិការក្រសួងការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ លោកជំទាវ **ឧត្តមសេនីយ៍ឯក** អគ្គលេខាធិការ គ.ជ.ប.ជ ឯកឧត្តម លោកជំទាវ ជាអគ្គលេខាធិការរង ប្រធានលេខាធិការដ្ឋាន នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ឯកឧត្តម **អគ្គនាយក** នៃនាយកដ្ឋាន អយ្យការ និងកិច្ចការព្រហ្មទណ្ឌ ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស ការពារអនីតិជនអគ្គនាយករង នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ តំណាងក្រសួងសង្គមកិច្ច ក្រសួងកិច្ចការនារី ក្រសួងអប់រំយុវជន និងកីឡា តំណាងចូលរួម អង្គការដៃគូពាក់ព័ន្ធមួយចំនួនទៀត។
- កិច្ចប្រជុំក្រុមការងារ បច្ចេកទេស គណៈកម្មការការពារកុមារថ្នាក់ជាតិដើម្បីពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងផែនការសកម្មភាពសម្រាប់អនុវត្តគោលនយោបាយជាតិស្តីពីប្រព័ន្ធកិច្ចការពារកុមារ **ឆ្នាំ២០១៩-២០២៩** ។ក្រោមអធិបតីភាព **លោកជំទាវ ញ៉េប សុភាព** អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន ក.ជ.ក និងក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ដោយមានការអញ្ជើញចូលរួម តំណាងក្រសួងស្ថាប័នពាក់ព័ន្ធ និងលោក លោកស្រីមួយចំនួនទៀតនៅសាលប្រជុំសាលាខេត្តព្រះវិហារ ៕

▪ **ក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ** លោកជំទាវ ឧត្តមសេនីយ៍ទោ **រ៉ន សិរីលក្ខិណា** អគ្គលេខាធិការរង បានអញ្ជើញចូលរួមៈ

- ក្នុងកិច្ចប្រជុំពិភាក្សាបន្តស្តីពីៈ "ផលប៉ះពាល់ នៃជំងឺកូវីដ-១៩ លើសិទ្ធិមនុស្សរបស់ជនទេសន្តរប្រវេសន៍ "ក្រោមអធិបតីភាព លោកជំទាវឧត្តមសេនីយឯក **ប៉ុណ្ណ សំខាន់** អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។
- កិច្ចប្រជុំជាមួយអង្គការដៃគូអភិវឌ្ឍន៍ជាតិ អន្តរជាតិតាមប្រពន្ធអនឡាញ )ZOOM ) ស្តីពីការ "ចែករំលែកព័ត៌មាន បទពិសោធន៍ និងធ្វើបច្ចុប្បន្នភាពការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆមាសទី១ និងទិសដៅឆមាសទី២ ឆ្នាំ២០២១" ក្រោមអធិបតីភាព លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ដោយមានការអញ្ជើញចូលរួមពី លោកជំទាវ ឧត្តមសេនីយឯក ប៉ុណ្ណ សំខាន់ អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។
- ពិធីចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នា រវាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអង្គការវីវើលអនឡូស WE WORLD ONLUS តំណាងភាគីខាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដឹកនាំដោយ លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ តំណាងភាគីខាងអង្គការវីវើលអនលូស )WE WORLD ONLUS) ដឹកនាំដោយ លោកស្រី Simona Capocasale ( Country Representation)។

- កិច្ចប្រជុំពិគ្រោះ យោបល់គុម្ពល តាមប្រព័ន្ធវីដេអូអនឡាញ «ស្តីពីគោលការណ៍មិន ដាក់ទណ្ឌកម្មលើជន រងគ្រោះដោយអំពើជួញដូរ» ក្រោមអធិបតីភាព លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ.និងមានការអញ្ជើញចូលរួមពីឯកឧត្តម ហ៊ុ វុឌ្ឍី រដ្ឋលេខាធិការ ក្រសួងការងារបណ្តុះបណ្តាលវិជ្ជាជីវៈ។
- វគ្គបណ្តុះបណ្តាលបន្តស្តីពី "ការប៉ះទង្គិចផ្លូវចិត្ត និងការអន្តរាគមន៍"។ វគ្គបណ្តុះបណ្តាលនេះធ្វើឡើងតាមរយៈអនឡាញ ដែលត្រូវបានរៀបចំឡើងដោយអង្គការបណ្តាញទូរស័ព្ទជំនួយកុមារកម្ពុជា ដែលត្រូវបានរៀបចំឡើងជាលើកទី៣ ជូនដល់មន្ត្រីពាក់ព័ន្ធដែលទទួលបានការបណ្តុះបណ្តាលកន្លងមក ដើម្បីចូលរួមផ្តល់ចំណេះដឹងជំនាញមូលដ្ឋានគ្រឹះនៃការពិគ្រោះយោបល់តាមទូរស័ព្ទ អំពើហិង្សាលើស្ត្រី ចំណាក ស្រុក ការប៉ះទង្គិចផ្លូវចិត្ត ព្រមទាំងជំនាញផ្តល់សេវាគាំទ្រ និងអន្តរាគមន៍ជាពិសេសសម្រាប់ស្ត្រី ពលករចំណាកស្រុក ដើម្បីរកការងារធ្វើនៅប្រទេសគោលដៅ និងប្រទេសកំណើតដែលជួបប្រទះបញ្ហាអំពើហិង្សាលើស្ត្រី អំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចកម្លាំងពលកម្ម។
- និងលោកឧត្តមសេនីយ៍ត្រី ប្រធានក្រុមជំនួយកិច្ចការ អំពីរបៀបរបបការងារ នៃការប្រព្រឹត្តិទៅរបស់មណ្ឌលទទួលពលករ និងការប្រគល់ទទួល សម្ភារៈបច្ចេកទេស ជូនបុគ្គលិក និងមន្ត្រីប្រចាំជូនមណ្ឌលទទួលពលករស្រុកកំរៀង ក្រោមអធិបតីភាព លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ និងមានការចូលរួមពីលោកអភិបាលស្រុកកំរៀង លោកជំទាវ ឧត្តមសេនីយ៍ឯក អគ្គលេខាធិការ អគ្គលេខាធិការរង ប្រធានក្រុមការងារព័ត៌មានវិទ្យា នៃអគ្គលេខាធិការដ្ឋាន លោកស្រីអភិបាលរងខេត្តបាត់ដំបង ស្នងការរងនគរបាលខេត្ត សហការីរបស់អង្គការកាតែសស្វីសអង្គការ Hagar អង្គការ A21 អង្គការសាម៉ារីតាន់កឺស អង្គការកុមាររីករាយ និងមន្ត្រីតំណាងពីមន្ទីរការងារ មន្ទីរសង្គមកិច្ច និងមន្ត្រីសាលាស្រុកកំរៀង។

▪ **ក្រុមជំនួយកិច្ចការអនុវត្តច្បាប់** ឯកឧត្តម អគ្គលេខាធិការរង **តែ សុថាវ៉េត** ទទួលបន្ទុកក្រុមការងារអនុវត្តច្បាប់បានចូលរួម៖

- កិច្ចប្រជុំពិភាក្សាបន្ថែសម្រាប់ត្រៀមកិច្ចប្រជុំពិគ្រោះ ស្តីពី «គោលការណ៍មិនដាក់ទណ្ឌកម្មលើជនរងគ្រោះដោយអំពើជួញដូរ»ក្រោមអធិបតីភាព លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ តាមប្រព័ន្ធអនឡាញ Zoom Video ដែលមានសមាសភាពអញ្ជើញចូលរួមពី លោកជំទាវអគ្គលេខាធិការ គជបជ ឯកឧត្តម លោកជំទាវតំណាងក្រសួងយុត្តិធម៌ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងកិច្ចការនារី អគ្គនាយកដ្ឋានអន្តោប្រវេសន៍ និងនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន **ផងដែរ។**
- ក្នុងជំនួបពិភាក្សាការងារ រវាងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ក្រោមអធិបតីភាពលោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ ជាមួយនិង លោកស្រីគ្រីស្ទីន ផាកូ ប្រធានអង្គការ(អាយអូអឹម) IOM ប្រចាំប្រទេសកម្ពុជា រួមនិងសហការី ពិភាក្សាអំពីកិច្ចសហការការងារជាមួយ គ.ជ.ប.ជ ពាក់ព័ន្ធលើកិច្ចការទេសន្តរប្រវេសន៍ និងគម្រោងត្រៀមកិច្ចប្រជុំបន្ត ស្តីពីកតិកាសញ្ញាសាកលពិភពលោកស្តីពីទេសន្តរប្រវេសន៍ដោយសុវត្ថិភាព រៀបរយ (GCM) ជាពិសេសគម្រោងផែនការអនុវត្តបន្តការងារមួយចំនួនទៀត។
- កិច្ចសម្ភាសន៍រវាងតំណាងអង្គការ Asean Actនិងអគ្គលេខាធិការដ្ឋាន នៃគណៈកម្មធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សតាមប្រព័ន្ធ អនឡាញ ដែលដឹកនាំដោយលោកជំទាវ ឧត្តមសេនីយឯក វេជ្ជ ប៊ុណ្ណ សំខាន់ អគ្គលេខាធិការ គជបជ និងឯកឧត្តមអគ្គលេខាធិការរង ឯកឧត្តមទីប្រឹក្សា ប្រធានក្រុមជំនួយកិច្ចការការពារជនរងគ្រោះ...។កិច្ចសម្ភាសន៍ស្តីពីវឌ្ឍនភាពនៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពីជួញដូរមនុស្ស ចាប់តាំងពីការបង្កើតឡើងរហូតដល់បច្ចុប្បន្ន និងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សក្នុងដំណាក់កាលការផ្ទុះរាលដាល ជម្ងឺកូវីដ១៩ និងការប្រឈមផ្សេងៗទៀតជាចំបង ការខិតខំប្រឹងប្រែង

របស់រាជរដ្ឋាភិបាល ក្នុងការប្តេជ្ញាចិត្ត ក្នុងការប្រយុទ្ធប្រឆាំងនិងអំពេើជួញដូរមនុស្សដែលមានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពេើជួញដូរមនុស្សជាសេនាធិការរបស់រាជរដ្ឋាភិបាល។

- កម្មវិធីសិក្ខាសាលាពិគ្រោះយោបល់ ស្តីពីតុលាការក្នុងការយកចិត្តទុកដាក់លើជនរងគ្រោះដោយអំពើជួញដូរមនុស្ស តាមប្រព័ន្ធអនឡាញ Zoom រៀបចំឡើងដោយ ASEAN-ACT គាំទ្រដោយក្រសួងយុត្តិធម៌ ក្រោមអធិបតីភាព ឯកឧត្តម ប៉ែន ពេជ្រសាលី អគ្គនាយកកិច្ចការអយ្យការ និងព្រហ្មទណ្ឌ នៃក្រសួងយុត្តិធម៌ និងជាប្រធានក្រុមការងារបច្ចេកទេស នៃកម្មវិធីអាស៊ាន-អូស្ត្រាលី ប្រឆាំងការជួញដូរមនុស្ស ASEAN-ACT ។ ដោយមានសមាសភាពចូលរួមពីភាគីពាក់ព័ន្ធក្នុង និងក្រៅប្រទេសចំនួនជាង១៨រូប។
- កិច្ចប្រជុំជាមួយអង្គការដៃគូអភិវឌ្ឍន៍ជាតិ អន្តរជាតិ តាមប្រពន្ធអនឡាញ(ZOOM) ស្តីពី ការចែករំលែកព័ត៌មាន បទពិសោធន៍ និងធ្វើបច្ចុប្បន្នភាពការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆមាសទី១ និងទិសដៅឆមាសទី២ ឆ្នាំ២០២១ ក្រោមអធិបតីភាព លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ដោយមានការអញ្ជើញចូលរួមពី លោកជំទាវអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ឯកឧត្តម លោកជំទាវ អគ្គលេខាធិការរង លោកទីប្រឹក្សាបច្ចេកទេស ប្រធាន អនុប្រធានលេខាធិការដ្ឋានរដ្ឋបាលសរុប ប្រធានក្រុមការងារទាំង៦ និងមានការចូលរួមពីតំណាងអង្គការដៃគូពាក់ព័ន្ធជាតិ អន្តរជាតិ តាមប្រពន្ធអនឡាញមួយចំនួន រួមទាំងមន្ត្រីពាក់ព័ន្ធ នៃអគ្គលេធិការដ្ឋាន គ.ជ.ប.ជ សរុបចំនួន ៤៧ រូប ។ កិច្ចប្រជុំនេះ ដើម្បីឲ្យអង្គការដៃគូបានជ្រាប និងចែករំលែកព័ត៌មានត្រឡប់ អំពីលទ្ធផលការងារ និងគម្រោងការនានាដែលអាចបន្សីគ្នា ឬផ្សាភ្ជាប់គ្នា ជាមួយថ្នាក់ជាតិ ក៏ដូចជាដំណោះស្រាយសម្រាប់ភាពប្រឈមនានា ដើម្បីបង្កើនប្រសិទ្ធិភាពការងារប្រឆាំងការជួញដូរមនុស្ស។
- ពិធីចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នា រវាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអង្គការវើលអនឡូស ។ ខាងភាគីគណៈកម្មាធិការជាតិ គ.ជ.ប.ជ ដឹកនាំដោយ លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ខាងភាគីអង្គការវើលអនលូស ដឹកនាំដោយ លោកស្រី Simona Capocasale ( Country Representation. ដោយមានការអញ្ជើញចូលរួមពី លោកជំទាវអគ្គលេខាធិការ គ.ជ.ប.ជ ឯកឧត្តម លោកជំទាវ អគ្គលេខាធិការរង ឯកឧត្តម ទីប្រឹក្សា និងលោក លោកស្រី ជាសហការី និងមន្ត្រីពាក់ព័ន្ធមួយចំនួនទៀត។
- កិច្ចប្រជុំពិគ្រោះយោបល់តុមូល តាមប្រព័ន្ធវីដេអូអនឡាញ «ស្តីពីគោលការណ៍មិន ដាក់ទណ្ឌកម្មលើជនរងគ្រោះដោយអំពើជួញដូរ» ក្រោមអធិបតីភាព លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ និងមានការអញ្ជើញចូលរួមពីឯកឧត្តម ហ៊ូ វុឌ្ឍី អនុរដ្ឋលេខាធិការក្រសួងការងារបណ្តុះបណ្តាលវិជ្ជាជីវៈ លោកជំទាវ ឧត្តមសេនីយ៍ឯក អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ឯកឧត្តម លោកជំទាវ ជាអគ្គលេខាធិការរង ប្រធានលេខាធិការដ្ឋាន នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ឯកឧត្តម អគ្គនាយក នៃនាយកដ្ឋានអយ្យការ និងកិច្ចការព្រហ្មទណ្ឌ ប្រធាននាយកដ្ឋាន ប្រឆាំងការជួញដូរមនុស្ស ការពារអនីតិជន អគ្គនាយករង នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ តំណាងក្រសួងសង្គមកិច្ច ជាប្រធាន នាយកដ្ឋានប្រឆាំងការជួញដូរ សមាហរនកម្មជនរងគ្រោះ តំណាងក្រសួងកិច្ចការនារី ជាប្រធាននាយកដ្ឋាន ប្រធាននាយកដ្ឋាននីតិកម្ម នៃក្រសួងអប់រំយុវជន និងកីឡា អ្នកសម្របសម្រួលគម្រោង AATIP គម្រោងអាស៊ាន អូស្ត្រាលីជាតំណាងចូលរួម និងតំណាងពីអង្គការដៃគូរពាក់ព័ន្ធ។
- កិច្ចប្រជុំស្តីពីផែនការសកម្មភាពការងារជាអទិភាពត្រូវអនុវត្ត និងអំពីរបៀបរបបការងារប្រចាំថ្ងៃរបស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ក្រោមអធិបតីភាពលោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ក្នុងកិច្ចប្រជុំនេះមានការអញ្ជើញចូលរួមពី លោកជំទាវអគ្គ លេខាធិការ គ.ជ.ប.ជ ឯកឧត្តម លោកជំទាវ អគ្គលេខាធិការរង និង ប្រធានក្រុមជំនួយកិច្ចការ ៦ នៃអគ្គលេខាធិការដ្ឋាន គ .ជ.ប.ជ ។

- កិច្ចប្រជុំ ស្តីពីផែនការសកម្មភាពការងារជាអទិភាពត្រូវអនុវត្តឆ្នាំ២០២១ និងឆ្នាំបន្ទាប់ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ក្រោមអធិបតីភាពលោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ក្នុងកិច្ចប្រជុំនេះមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ អគ្គលេខាធិការរង ប្រធានលេខាធិការដ្ឋាន រដ្ឋាបាល-សរុប និងប្រធានក្រុមជំនួយកិច្ចការ ៦ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។
- កិច្ចប្រជុំ ស្តីពីផែនការសកម្មភាពការងារជាអទិភាពត្រូវអនុវត្តនៅឆមាសទី២ ឆ្នាំ២០២១ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ក្រោមអធិបតីភាព លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ក្នុងកិច្ចប្រជុំនេះមានការអញ្ជើញចូលរួមពី លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជ.ប៉ុណ្ណ សំខាន់ អគ្គលេខាធិការ ឯកឧត្តម លោកជំទាវ អគ្គលេខាធិការរង ប្រធានក្រុមជំនួយកិច្ចការ នៃក្រុមជំនួយកិច្ចទាំង៦ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។

▪ **ក្រុមជំនួយកិច្ចការទេសន្តរប្រវេសន៍** ឯកឧត្តម អគ្គលេខាធិការរង ទទួលបន្ទុកក្រុមការងារបានចូលរួមកិច្ចប្រជុំ៖

- ត្រៀមពិគ្រោះយោបល់តុមូលស្តីពីគោលការណ៍មិនដាក់ទណ្ឌកម្មលើជនរងគ្រោះដោយអំពើជួញដូរមនុស្ស ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ តាមប្រព័ន្ធអនឡាញ (Zoom Video) នៅសាលបរជុំរបស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។
- ឆ្លើយសំណួររបស់អង្គការ Asean Act ស្តីពីវឌ្ឍនៈភាពការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរបស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ក្រោមអធិបតីភាពលោកជំទាវ ឧត្តមសេនីយ៍ឯក អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ នៅសាលប្រជុំរបស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ។
- បន្តកែសម្រួល ចំឡើយសម្រាប់សំណួររបស់អង្គការ Asean Act ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់លោកជំទាវ ឧត្តមសេនីយ៍ឯក អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ នៅសាលប្រជុំរបស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ។
- ពិភាក្សាស្តីពី "ផលប៉ះពាល់នៃជំងឺកូវីដ-១៩ លើសិទ្ធិមនុស្សរបស់ជនទេសន្តរប្រវេសន៍" ក្រោមការដឹកនាំរបស់លោកជំទាវ ឧត្តមសេនីយ៍ឯក ប៉ុណ្ណ សំខាន់ អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ នៅសាលប្រជុំរបស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។
- ជាមួយអង្គការដៃគូអភិវឌ្ឍន៍ជាតិ អន្តរជាតិ តាមប្រព័ន្ធអនឡាញ (Zoom) ស្តីពីការចែករំលែកព័ត៌មានបទពិសោធន៍ និងការធ្វើបច្ចុប្បន្នភាពការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆមាសទី១ ទិសដៅឆមាសទី២ ឆ្នាំ២០២១ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅសាលប្រជុំរបស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។
- ពិនិត្យកែសម្រួលខ្លឹមសារ និងអក្ខរាវិរុទ្ធសេចក្តីព្រាងអនុស្សរណៈរវាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអង្គការវើលអនលូស ជាមួយលោកកែប សារឿន ទីប្រឹក្សាបច្ចេកទេសរបស់ គ.ជ.ប.ជ ។
- ពិនិត្យកែសម្រួលសំណួរ ចម្លើយឆ្លើយបតទៅនឹងអង្គការ Asean-Act ក្រោមអធិបតីភាពលោកជំទាវ ឧត្តមសេនីយ៍ឯក អគ្គលេខាធិការ គ.ជប.ជ ។
- ស្តីពីផែនការសកម្មភាពការងារជាអាទិភាពត្រូវអនុវត្ត និងអំពីរបៀបរបបការងារប្រចាំថ្ងៃរបស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅសាលប្រជុំរបស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។
- ស្តីពីផែនការសកម្មភាពការងារជាអាទិភាពត្រូវអនុវត្តក្នុងឆ្នាំ២០២១ និងលើកទិសដៅឆ្នាំបន្ទាប់ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅសាលប្រជុំរបស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។

| | |
|---|---|
| | - បានបញ្ជូនលិខិតទៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីស្នើសុំការចាត់អញ្ជើញ **ឯកឧត្តម ហ៊ូ វុទ្ធី** រដ្ឋលេខាធិការ ចូលរួមកិច្ចប្រជុំពិភាក្សាពិគ្រោះយោបល់គុមូលស្ព័ពី "គោលការមិនដាក់ទណ្ឌកម្មលើជនរងគ្រោះដោយអំពើជួញដូរមនុស្ស" តាមប្រព័ន្ធអនឡាញ (Zoom) ។<br>- បានបូកសរុបស្ថិតិប្រជាពលរដ្ឋកម្ពុជា ដែលបានវិលត្រឡប់មកពីក្រៅប្រទេសក្នុងអំឡុងពេលនៃការរីករាលដាលនៃជំងឺកូវីដ-១៩ ជាប្រចាំថ្ងៃទាំង២៥ រាជធានីខេត្ត ជូនលោកជំទាវអនុប្រធានអចិន្ត្រៃយ៍ និងលោកជំទាវ ឧត្តមសេនីយ៍ឯក អគ្គលេខាធិការ គ.ជ.ប.ជ បានចំនួន ១៤,៥៨៤នាក់ (ស្រី ៦,៩២៩នាក់) គិតចាប់ពីថ្ងៃទី០១ ដល់ថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ២០២១ ។ |
| **លេខធិការដ្ឋាន គ.ខ.ប.ជ សម្របសម្រួលចំនួន ២១លើក អ្នកចូលរួមសរុបចំនួន ៥១០នាក់ (ស្រី ២០៤នាក់)** | |
| **ខេត្តកណ្តាល** | - លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ប្រចាំខែមិថុនា ត្រីមាសទី២ និងឆមាសទី១ និង លើកទិសដៅអនុវត្តបន្ត ឆ្នាំ២០២១ ចំនួន០១លើក អ្នកចូលរួមចំនួន**៥៦**នាក់ ស្រី២៨នាក់។<br>- បានរៀបចំកិច្ចប្រជុំផ្សព្វផ្សាយផែនការកិច្ចការពារកុមារថ្នាក់ខេត្ត ផ្តោតលើការថែទាំជំនួស និងអំពើហិង្សាលើកុមារ ចំនួន០១លើក អ្នកចូលរួមចំនួន**៥៧**នាក់ ស្រី**២៥**នាក់។<br>- ក្រុមការងារក្រុង-ស្រុក បានប្រជុំប្រចាំខែ ចំនួន**០២**លើក អ្នកចូលរួម**៥៧**នាក់ ស្រី២**៣**នាក់។ |
| **ខេត្តសៀមរាប** | - លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំ ស្តីពីលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ប្រចាំឆមាសលើកទី១ ចំនួន០១លើក អ្នកចូលរួមចំនួន**៦៣**នាក់ ស្រី**៣៧**នាក់។<br>- លេខាធិការដ្ឋាន គ.ខ.ប.ជ បានចូលរួមកិច្ចប្រជុំ សិក្ខាសាលា ជាមួយក្រសួង ស្ថាប័ន និងអង្គការដៃគូ ពាក់ព័ន្ធនឹងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ចំនួន០៥លើក។ |
| **ខេត្តបាត់ដំបង** | - បានដឹកនាំកិច្ចប្រជុំពិភាក្សា ស្តីពីការបង្ក្រាបបទល្មើសឆ្លងដែនខុសច្បាប់គ្រប់ប្រភេទនៅភូមិសាស្ត្រ ស្រុកកំរៀង ស្រុកភ្នំព្រឹក ស្រុកសំពៅលូន និងស្រុកសំឡូត ដើម្បីពង្រឹងសមត្ថភាពការងាររបស់មន្ត្រីដែលមានតួនាទីការកិច្ចនៅព្រំដែន។ |
| **ខេត្តកំពង់ចាម** | - បានចូលរួមវគ្គបណ្តុះបណ្តាលចំនួន០៣លើក ស្តីពីចំណេះដឹងក្នុងការគ្រប់គ្រងការងារទេសន្តរប្រវេសន៍ ការដោះស្រាយវិវាទ ព្រមទាំងការផ្តល់សេវាគាំទ្រដល់ពលករ ដែលរៀបចំដោយអង្គការ OLO, Legal Aids និង LSCW អ្នកចូលរួមចំនួន**១១០**នាក់ ស្រី**៤៦**នាក់។ |
| **ខេត្តកំពង់ឆ្នាំង** | - លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំតាមប្រព័ន្ធវីដេអូ ជាមួយនឹងមន្ត្រីថ្នាក់ក្រុង ស្រុក ចំនួន០៥លើក ពាក់ព័ន្ធនឹងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងការងាររដ្ឋបាលផ្សេងៗ អ្នកចូលរួមចំនួន**១៣៩**នាក់ ស្រី៤៥នាក់។ |